# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jan-2012, 13:08
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សាធារណៈ

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# បណ្ដឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលជំនុំជម្រះក្ដី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្ដីរបស់គាត់ដោយខ្លួនគាត់

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដី៖**

អាង ឧត្ដម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រម គង់ ស្រីម**

**ចៅក្រម សោម សេរីវុឌ្ឍ**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម យ៉ា ណារិន**

**ចៅក្រម MOTOO Noguchi**

---

**ចៅក្រម Agnieszka KLONOWIECKA-MILART**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រមបម្រុង ស៊ិន រិទ្ធិ**

**ចៅក្រម បម្រុង Florence MUMB**

**សហព្រះរាជអាជ្ញា ៖**

**ជា លាន**

Andrew CAYLEY

**ក្រុមសហមេធាវីការពារក្ដីទាំងអស់**

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់៖**

តាមរយៈសហមេធាវីការពារក្ដីរបស់គាត់(“សហមេធាវីការពារក្ដី”) អនុលោមតាមវិធាន ១០៤ (១) វិធាន ១០៤(៤)(ឃ) វិធាន ១០៥(២) និងវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) លោក អៀង សារី ប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលជំនុំជម្រះក្ដី និងបានបដិសេធសិទ្ធិជួយការពារក្ដីរបស់គាត់ដោយខ្លួនគាត់ ដែលជាសិទ្ធិត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”)[១]។ បណ្ដឹងសាទុក្ខនេះ ត្រូវបានធ្វើឡើងជាការចាំបាច់ ដោយសារតែមានកំហុសអង្គច្បាប់ដែលនាំឱ្យសេចក្ដីសម្រេចនោះក្លាយជាមោឃៈ និងដោយសារតែមានកំហុសអង្គហេតុដែលបណ្ដាលឱ្យសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ និងការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី។ សេចក្ដីសម្រេចដែលត្រូវបានជំទាស់នោះ គឺជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដែលរំលោភបំពាន ក) សិទ្ធិរបស់លោក អៀង សារី ក្នុងការលះបង់សិទ្ធិមាន វត្តមានក្នុងពេលជំនុំជម្រះក្ដីរប**ស់គាត់ និង ខ**) សិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ គឺសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធិជួយការពារក្ដីរបស់គាត់ដោយខ្លួនគាត់។ សហមេធាវីការពារក្ដីសូមបញ្ចូលដោយយោងទៅទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ទាំងអស់ ដែលសហមេធាវីការពារក្ដីបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខនេះ[២]។

## I. មូលដ្ឋាននៃបណ្ដឹងសាទុក្ខ

---

[១] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E1/13.1 (“ប្រតិចារឹកថ្ងៃទី ២១ ខែ វិច្ឆិកា”) ទំព័រទី ៣៦។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E1/14.1 (“ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា”) ទំព័រទី ៨។

[២] ការកត់សម្គាល់របស់លោក អៀង សារី ស្ដីពីថាតើអង្គជំនុំជម្រះសាលាដំបូងអាចចាប់បង្ខំជនជាប់ចោទឱ្យមានវត្តមានក្នុងតុលាការដែរឬយ៉ាងណា នៅពេលដែលជនជាប់ចោទបានសុំលះបង់ដោយចេតនាស្ម័គ្រចិត្តពិតប្រាកដ នូវសិទ្ធិមានវត្តមានរបស់គាត់ ហើយត្រូវបានតំណាងការពារដោយមេធាវី ឯកសារចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E130។ *សូម មើលផងដែរ* ប្រតិចារឹកសវនាការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/14.1 ទំព័រ ៦៥-៦៧, ៦៩-៧០ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ១-៣

ក) នៅ អ.វ.ត.ក ដោយអនុលោមតាមច្បាប់អន្តរជាតិ សិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់ គឺជាសិទ្ធិដាច់ខាត និងត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា និងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក។ ដោយសារបញ្ហាសុខភាពលោក អៀង សារី មិនអាចចូលរួម ឬជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់ ដោយត្រូវអង្គុយក្នុងបន្ទប់សវនាការគ្រប់ពេលបាននោះទេ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬទេ នៅពេលដែលខ្លួនបានចាប់បង្ខំលោក អៀង សារី ឱ្យមានវត្តមាននៅក្នុងសាលសវនាការគ្រប់ពេល ជាជាងអនុញ្ញាតឱ្យគាត់ចូលរួម និងជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់ពីបន្ទប់រង់ចាំដែលមានបំពាក់ឧបករណ៍ពិសេស?

ខ) វិធានផ្ទៃក្នុង និងវិធាននីតិវិធី យុត្តិសាស្ត្រ និងការអនុវត្ត សុទ្ធតែអនុញ្ញាតឱ្យលោក អៀង សារី អាចលះបង់សិទ្ធិមានវត្តមានរបស់គាត់ក្នុងពេលជំនុំជម្រះក្តីបាន នៅពេលគាត់ត្រូវបានតំណាងការពារក្តីដោយមេធាវី។ តាមរយៈសហមេធាវីការពារក្តីរបស់គាត់ លោក អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ និងដោយសារបញ្ហាសុខភាព គាត់បានស្នើសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ ដោយប្រើឧបករណ៍តាមដានការជំនុំជម្រះក្តី។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬទេ នៅពេលដែលខ្លួនបានបដិសេធការសុំលះបង់សិទ្ធិរបស់លោក អៀង សារី និងចាប់បង្ខំឱ្យគាត់មានវត្តមាននៅក្នុងសាលសវនាជានិច្ចដូច្នេះ?

គ) រដ្ឋធម្មនុញ្ញកម្ពុជា ក៏ដូចជាក្របខណ្ឌច្បាប់របស់ អ.វ.ត.ក គឺសុទ្ធតែហាមឃាត់ការដាក់ទណ្ឌកម្មណាមួយមកលើលោក អៀង សារី ប្រសិនបើពុំមានច្បាប់ចែង។ អង្គជំនុំជម្រះសាលាដំបូងបានចាប់បង្ខំលោក អៀង សារី ឱ្យមានវត្តមានក្នុងសាលសវនាការគ្រប់ពេល។ បើទោះបីជាឃើញគាត់មានការឈឺចាប់ផ្នែករាងកាយយ៉ាងណាក្តី ក៏អង្គជំនុំជម្រះនៅតែបដិសេធពាក្យសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់។ តើអង្គជំនុំជម្រះសាលាដំបូងពិតជាមានកំហុសដែរឬទេ នៅពេលដែលខ្លួនបានដាក់ទណ្ឌកម្មលើលោក អៀង សារី ដោយពុំមានច្បាប់ចែងឱ្យធ្វើដូច្នេះយ៉ាងណាក៏ដោយនោះ?

ឃ) *រដ្ឋធម្មនុញ្ញកម្ពុជា និងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ហាមឃាត់មិនឱ្យប្រើវិធានការបង្ខំដែលកំពុងត្រូវបានអនុវត្តចំពោះលោក អៀង សារី ដែលមិនបានអនុវត្តយ៉ាងតឹងរឹងបំផុតចំពោះតែតម្រូវការចាំបាច់នៃកិច្ចដំណើរការនីតិវិធី ឬមិនគោរពយ៉ាងពេញលេញចំពោះសេចក្ដីថ្លៃថ្នូររបស់មនុស្សឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានចាប់បង្ខំលោក អៀង សារី ឱ្យមានវត្តមានក្នុងសាលសវនាការ ទោះជាគាត់មានបញ្ហាសុខភាពរាងកាយយ៉ាងធ្ងន់ធ្ងរ ដោយមិនអើពើការបោះបង់សិទ្ធិមានវត្តមានរបស់គាត់ឡើយ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬទេ នៅពេលដែលខ្លួនដាក់លោកអៀង សារី ឱ្យនៅក្រោមវិធានបង្ខំ ដែលមិនបានអនុវត្តយ៉ាងតឹងរឹងបំផុតចំពោះតែតម្រូវការចាំបាច់នៃកិច្ចដំណើរការនីតិវិធី ឬមិនគោរពយ៉ាងពេញលេញចំពោះសេចក្ដីថ្លៃថ្នូររបស់មនុស្សនោះ?*

ឃ) *អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយផ្ដល់សារៈសំខាន់ដល់កត្តាមិនពាក់ព័ន្ធ ឬមិនសំខាន់ផ្សេងៗ នៅក្នុងការចេញសេចក្ដីសម្រេចមួយ និងខកខានមិនបានផ្ដល់សារៈសំខាន់ ឬមិនបានផ្ដល់សារៈសំខាន់គ្រប់គ្រាន់ដល់កត្តាពាក់ព័ន្ធនានា។ អង្គជំនុំជម្រះសាលាដំបូង បានចាប់បង្ខំលោក អៀង សារី ឱ្យមានវត្តមានក្នុងសាលសវនាការ ទោះជាគាត់មានបញ្ហាសុខភាពរាងកាយយ៉ាងធ្ងន់ធ្ងរ ដើម្បីឱ្យសាធារណៈជន និងភាគីដទៃ អាចមើលឃើញថាលោក អៀង សារី កំពុងស្ដាប់បទចោទប្រកាន់រូបគាត់។ តើអង្គជំនុំជម្រះសាលាដំបូង បានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយបំពេញបំណងរបស់សាធារណៈជន និងភាគីដទៃ ដោយមិនគិតពីស្ថានភាពសុខភាព និងសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោក អៀង សារីនោះ?*

## II. សង្ខេបនត្ថិករណ៍

១ នៅពេលអង្គជំនុំជម្រះសាលាដំបូងចាប់បង្ខំឱ្យលោក អៀង សារី មានវត្តមានគ្រប់ពេលនៅក្នុងសាលសវនាការ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិដាច់ខាតដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងមកលើរូបគាត់ និងសិទ្ធិអាចសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់ក្នុង

ពេលជំនុំជម្រះក្តី។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ ពិតជាបានរំលោភបំពានលើធន្ទានុសិទ្ធិ និងជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។

២ លោក អៀង សារី ទទួលបានសិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិដាច់ខាតដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងលើគាត់ និងសិទ្ធិជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់។ សិទ្ធិនេះត្រូវបានធានានៅក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក និងកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”)។ ការចាប់បង្ខំឲ្យគាត់មានវត្តមានដោយផ្ទាល់នៅក្នុងសាលសវនាការ ខៈណៈពេលគាត់កំពុងមានបញ្ហាសុខភាព គឺគាត់ពិតជាមិនអាចចូលរួមក្នុងស្ថានភាពផ្លូវចិត្តល្អបាននោះទេ និងគាត់មិនអាចចូលរួម និងជួយការពារក្តីរបស់គាត់បាននោះដែរ។

៣ អនុលោមតាមវិធានផ្ទៃក្នុង និងនីតិវិធី ការអនុវត្ត និងយុត្តិសាស្ត្រអន្តរជាតិ លោក អៀង សារី មានសិទ្ធិលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការ ប្រសិនបើគាត់សុំលះបង់សិទ្ធិនេះដោយស្ម័គ្រចិត្ត ដោយដឹងច្បាស់ជាមុន និងដោយឥតមន្ទិល ហើយត្រូវបានតំណាងការពារក្តីដោយមេធាវី។ អង្គជំនុំជម្រះសាលាដំបូង បានរំលោភបំពានសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួម និងសិទ្ធិជួយការពារក្តីរបស់គាត់ និងសិទ្ធិលះបង់សិទ្ធិមានវត្តមានរបស់គាត់ ដោយអង្គជំនុំជម្រះបានបដិសេធពុំព្រមទទួលស្គាល់ការសុំលះបង់សិទ្ធិរបស់គាត់ និងចាប់បង្ខំឲ្យគាត់មានវត្តមានក្នុងសាលសវនាការ។

៤ ក្នុងការចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ អង្គជំនុំជម្រះសាលាដំបូងបានចាប់បង្ខំឲ្យលោក អៀង សារី មានវត្តមានគ្រប់ពេលក្នុងសាលសវនាការ ទោះបីជាមើលឃើញថាគាត់មានការឈឺចាប់ផ្នែករាងកាយក៏ដោយ។ នេះគឺជាការមិនអើពើមួយចំពោះពាក្យសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់។ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារតែខ្លួនបានដាក់ទណ្ឌកម្មមកលើរូបលោក អៀង សារី និងបានអនុវត្តវិធានការចាប់បង្ខំមកលើរូបគាត់ ដែលទង្វើបែបនេះគឺពុំមានចែងក្នុងច្បាប់ និងពុំបានគោរពដល់សេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្សរបស់គាត់។ វិធានការ

ចាប់បង្ខំបែបនេះ គឺគេអាចអនុវត្តបានយ៉ាងតឹងរឹងបំផុតចំពោះតែតម្រូវការចាំបាច់នៃកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ។

៥ ក្នុងការចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ អង្គជំនុំជម្រះសាលាដំបូង បានឲ្យតម្លៃហួសហេតុពេកទៅលើសេចក្តីប្រាថ្នា និងការរំពឹងទុករបស់សាធារណជន និងភាគីដទៃទៀត ប៉ុន្តែបែរជាមិនបានគិតគូរល្អិតល្អន់ចំពោះបញ្ហាសុខភាពរបស់លោក អៀង សារី ជាពិសេសគឺសិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិដាច់ខាតជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិរបស់គាត់ក្នុងការទទួលបានការប្រព្រឹត្តមកលើរូបគាត់ដោយសេចក្តីថ្លៃថ្នូរជាមនុស្ស។ អង្គជំនុំជម្រះសាលាដំបូងរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានចាប់បង្ខំឲ្យលោក អៀង សារី មានវត្តមានក្នុងសាលសវនាការ ទោះបីតែគាត់មានបញ្ហាសុខភាពរាងកាយដែលមិនអាចឲ្យគាត់មានវត្តមាននៅក្នុងសវនាការពេញលេញយ៉ាងណាក៏ដោយ។ ការអនុញ្ញាតឲ្យលោក អៀង សារី ចូលរួមពីចម្ងាយពីបន្ទប់រង់ចាំ គឺជាជម្រើសមួយសមស្រប ជាជាងចាប់បង្ខំគាត់ឲ្យមានវត្តមានដោយផ្ទាល់ក្នុងសាលសវនាការ។ កំហុសឆ្គងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដូចនេះ គឺជាការប៉ះពាល់ដល់លោក អៀង សារី យ៉ាងប្រត្យក្ស។

## III. បញ្ហាបឋម

### ក) ភាពទទួលយកបាននៃបណ្តឹងសាទុក្ខ

៦ មូលដ្ឋាននៃបណ្តឹងសាទុក្ខ គឺពាក់ព័ន្ធនឹងការជ្រៀតជ្រែករបស់អង្គជំនុំជម្រះសាលាដំបូងក្នុងកិច្ចការរដ្ឋបាលតុលាការ ដែលការជ្រៀតជ្រែកនេះគឺអង្គជំនុំជម្រះសាលាដំបូងបានដឹងច្បាស់ជាមុន និងបានធ្វើឡើងដោយចេតនា។ ជាលទ្ធផល សិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិដាច់ខាតជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងមកលើរូបគាត់ និងដើម្បីជួយការពារក្តីរបស់គាត់ ត្រូវបានរំលោភបំពាន។ អង្គជំនុំជម្រះសាលាដំបូង មានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ និងបាន

រំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានបដិសេធសំណើរបស់លោក អៀង សារី ដែលបានស្នើសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ និងដោយបានចាប់បង្ខំឲ្យគាត់មានវត្តមានគ្រប់ពេលនៅក្នុងសាលសវនាការ។ កំហុសឆ្គងទាំងអស់នេះ គឺពាក់ព័ន្ធនឹងការដែលអង្គជំនុំជម្រះ មិនអើពើចំពោះសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី គឺសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិចូលរួម និងជួយការពារក្តីរបស់គាត់ និងសិទ្ធិក្នុងការលះបង់សិទ្ធិមានវត្តមាននៅក្នុងសាល សវនាការ។ កំហុសឆ្គងទាំងនេះ ប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី និងបានដកហូតដោយដឹងច្បាស់ជាមុន និងដោយចេតនា នូវសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលជាសិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ កំហុសបែបនេះមិនអាចជួសជុលបាននោះទេ លើកលែងតែវាត្រូវបានដោះស្រាយតាមមធ្យោបាយបន្ទាន់បង្គំមួយ។ មូលដ្ឋាននៃបណ្តឹងសាទុក្ខនេះ អាចទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(១) វិធាន ១០៤(ឃ) និងវិធាន ១០៥(២)[៣]។

៧ សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ គឺប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមឲ្យមានប្រសិទ្ធិភាព ក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់ និងជួយក្នុងការការពារក្តីរបស់គាត់ដោយខ្លួនគាត់។ ការដែលអង្គជំនុំជម្រះសាលាដំបូងមិនបានយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ចំពោះស្ថានភាពសុខភាពរបស់លោក អៀង សារី[៤] និងការដែលចាប់បង្ខំគាត់ឲ្យមានវត្តមានដោយផ្ទាល់នៅក្នុងសាលសវនាការ ដោយសារតែសវនាការនោះគឺជាសវនាការស្តីពី“សេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ" និងដើម្បី“បញ្ជាក់ឲ្យភាគី និងសាធារណជនឃើញថា

[៣] វិធាន ១០៥(២) ចែងថា ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់បណ្តឹងសាទុក្ខភ្លាមៗនោះ ដោយ ក) បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនេះបណ្តាលសេចក្តីសម្រេចមានមោឃៈភាព ឬ ខ) បញ្ជាក់អំពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ឬ គ) បញ្ជាក់អំពីកំហុសអង្គហេតុ និងត្រូវបង្ហាញថាកំហុសនេះ នាំឲ្យមានការភ័ន្តច្រឡំក្នុងការសម្រេចសេចក្តីរបស់តុលាការ។

[៤] *សូមមើល* របាយការណ៍ដែលបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E62/3 (ឯកសារសម្ងាត់) ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E62/3/5 (“របាយការណ៍របស់លោក Campbell”) ប្រតិចារឹកចុះថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រទី ៣៦ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រទី ១-៣។

[លោក អៀង សារី] ពិតជាបានស្តាប់ឮបទចោទ”ប្រឆាំងនឹងគាត់[៥] អង្គជំនុំជម្រះសាលាដំបូងរារាំងមិនឱ្យលោក អៀង សារី ចូលរួមដោយសុទ្ធចិត្ត និងមិនឱ្យគាត់ចូលរួមបានពេញលេញក្នុងកិច្ចដំណើរការនីតិវិធី ដែលជាសិទ្ធិដែលគាត់ត្រូវទទួលបានដូចមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ មានកំហុសឆ្គងអង្គច្បាប់ដែលបណ្តាលឱ្យទៅជាមោឃៈភាព[៦] និងកំហុសអង្គច្បាប់ដែលបណ្តាលឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌[៧]។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខឆ្លាមៗ អាចដាក់បាន ដោយអនុលោមតាមវិធាន ១០៤(១) ។ ការដែលអង្គជំនុំជម្រះសាលាដំបូងឱ្យតម្លៃលើសេចក្តីប្រាថ្នារបស់សាធារណជន និងភាគីដទៃទៀត ជាងសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការចូលរួម និងជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់ អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្ត“កំហុសឆ្គងពិតប្រាកដ”ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ប៉ះពាល់ដល់លោក អៀង សារី[៨]។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ គឺអាចប្តឹងសាទុក្ខឆ្លាមៗបាន ដោយអនុលោមតាមវិធាន ១០៤(១) ដោយសារតែនេះជាការរំលោភបំពានលើឆន្ទានុសិទ្ធិដែលនាំឱ្យប៉ះពាល់ដល់លោក អៀង សារី។

៨ សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ គឺអាចប្តឹងសាទុក្ខឆ្លាមៗបាន ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ដែលការរំលោភនេះបង្កើតបានជាការជ្រៀតជ្រែកដល់ដំណើរការយុត្តិធម៌

---

[៥] ប្រតិចារឹកថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៨។ ដំណាក់កាលនៃការជំនុំជម្រះក្តីនេះ ពុំមែនជាកាលៈទេសៈដំបូងដែលលោក អៀង សារី បានឮបទចោទប្រឆាំងរូបគាត់នោះទេ។ គាត់ត្រូវបានជម្រាបអំពីបទចោទប្រឆាំងរូបគាត់នេះនៅមុនការចាប់ផ្តើមការជំនុំជម្រះក្តីនេះ គឺក្នុងសវនាការសាធារណៈជាច្រើន និងតាមរយៈការចេញដីកាដំណោះស្រាយ។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវនាការដេញដោល ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ C19 ទំព័រទី២ កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ D282 ទំព័រទី ៣-៥។ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 សវនាការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ ឯកសារ E1/4.1 ទំព័រទី ១។

[៦] វិធាន ១០៤(១)(ក)

[៧] វិធាន ១០៤(១)(ខ)

[៨] វិធាន ១០៤ (១)

តុលាការ[៩]។ ផ្ទុយទៅនឹងការបកស្រាយរបស់អង្គបុរេជំនុំជម្រះ[10] នៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬកិច្ចព្រមព្រៀង ឬវិធានផ្ទៃក្នុង ពុំមានចែងអំពីបទប្បញ្ញត្តិណាមួយដែលហាមឃាត់ការអនុវត្តវិធាន ៣៥ ប្រឆាំងនឹងអង្គជំនុំជម្រះសាលាដំបូងនោះទេ[11]។ អភ័យឯកសិទ្ធិដែលមានចែងក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង[12] មិនមានមុខងាររារាំងភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខនេះទេ ដោយហេតុថា៖ **ក.** សំណើដែលបានលើកឡើងមិនស្នើឲ្យដាក់ទណ្ឌកម្មជាការជួសជុលព្យសនកម្មឡើយ ប៉ុន្តែគ្រាន់តែស្នើឲ្យកែប្រែកំហុសរបស់ចៅក្រម និង **ខ.** អង្គជំនុំជម្រះសាលាដំបូងបានប្ដឹងបុគ្គលិកអន្តរជាតិ អនុលោមតាមវិធាន ៣៥ ទោះបីជាគាត់ទទួលបានអភ័យឯកសិទ្ធិក្នុងដំណើរការច្បាប់ ដែលផ្ដល់ឲ្យបុគ្គលិកអន្តរជាតិ អនុលោមតាមវិធាន ៤២ ថ្មី (២) (ក) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក និងមាត្រា ២០ (២) (ក) នៃកិច្ចព្រមព្រៀង[13]។

---

[៩] វិធាន ១០៤ (៤) (គ)

[10] *សូមមើល* សាលដីកាសម្រេចលើសំណើលោកអៀង សារី ស្នើសុំឲ្យអនុវត្តវិធាន៣៥ ដើម្បីផិតចិត្តលោកចៅក្រម *Marcel Lemonde* សំណុំរឿង០០២/០៧-១២-២០០៩ អ.វ.ត.ក/អ.ប.ជ ៥ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៩ (សាលដីកា សម្រេច លើ បណ្ដឹងផិតផិតលោកចៅក្រម *Lemonde* ) កថាខណ្ឌ ១១ ១៤៖ "គ្មានយុត្តាធិការដែលត្រូវបានចែងសម្រាប់អង្គជំនុំជម្រះណាមួយរបស់ អ.វ.ត.ក ដើម្បីដោះស្រាយចំពោះបញ្ហាវិន័យសម្រាប់ចៅក្រមណាមួយនៅ អ.វ.ត.ក ឡើយ...។ ដោយសារតែសំណើនេះព្យាយាមសុំផិតចិត្តលោកចៅក្រម *Lemonde* ជាការដាក់ទណ្ឌកម្មទៅតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ផ្អែកទៅលើឥរិយាបទរបស់ចៅក្រមនៅក្នុងសំណុំរឿងរបស់គាត់ ដែលសហមេធាវីកំណត់ថាមានន័យថាជាការរំខានការស្វែងរកយុត្តិធម៌ ដូច្នេះសំណើនេះមិនត្រូវបានទទួលយកទេ។

[11] ដោយពិចារណាទៅលើវិធាន ២១ វិធាន ៣៥ ត្រូវតែបែងចែកចេញពីវិធាន ៧៧ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់សាលាក្ដី ICTY។ វិធាន ៧៧ របស់សាលាក្ដី ICTY ពាក់ព័ន្ធនឹង"អំណាចដែលមានស្រាប់"របស់សាលាក្ដីអន្តរជាតិក្នុងការ"ប្ដឹងពីបទប្រមាថតុលាការ"ចំពោះជនណាដែលមានចេតនាពិតប្រាកដក្នុងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ខ្លឹមសារសាមញ្ញ និងទូទៅនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បង្ហាញថាកិច្ចដំណើរការនីតិវិធីដែលអនុលោមតាមវិធាននេះ គឺមិនមែនអនុវត្តបានត្រឹមតែជនទាំងឡាយណាដែលត្រូវបានសង្ស័យថាប្រមាថតុលាការនោះប៉ុណ្ណោះទេ ដោយសារតែវិធាននេះពុំមាននិយាយអំពីប្រធានបទនេះ។ អំណាចដែលមានស្រាប់ណាមួយរបស់ អ.វ.ត.ក ក្នុងការស្វែងរកជនណាម្នាក់ដែលទទួលខុសត្រូវពីបទប្រមាទតុលាការ គឺជាអំណាចដាច់ដោយឡែកមួយ និងដាច់គ្នាពីអំណាចរបស់អង្គជំនុំជម្រះក្នុងការស្វែងរកជនណាម្នាក់ដែលទទួលខុសត្រូវចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការដោយមានចេតនាពិតប្រាកដ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។

[12] ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក មាត្រា ៤១ និង៤២ ថ្មី កិច្ចព្រមព្រៀង មាត្រា ១៩ និង ២០

[13] *សូមមើល* សំណុំរឿង 002/14-12-2009-ECCC/PTC (08)

៩ ចៅក្រមអាចនឹងរំលោភលើសិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយពុំចាំបាច់ប្រព្រឹត្តអំពើពុករលួយ ឬមានចេតនាទុច្ចរិត ពោលគឺមានភាពប្រទ្បាក់ប្រទ្បូសដោយភាពលម្អៀង ឬលេចឡើងនូវភាពលម្អៀង។ វាជាកំហុសឆ្គងមួយដែលសន្និដ្ឋានថា យុត្តាធិការដែលពិចារណាទៅលើឥរិយាបថរបស់ចៅក្រមនៅក្នុងសំណុំរឿងដែលខ្លួនដំណើរការ ត្រូវបានកំណត់ត្រឹមតែការអនុវត្តនូវការប្តឹងជិតចិត្ត[14]តាមវិធាន ៣៤ នោះ។ គេត្រូវបែងចែកឲ្យបានច្បាស់លាស់ បើមិនដូច្នេះទេការជំទាស់ដែលមានធម្មានុភាពទៅលើការរំលោភបំពានរបស់ចៅក្រមនៅក្នុងដំណាក់កាលបន្ទាន់បង្ហំ ត្រូវបានបដិសេធចោលភ្លាមៗ លើកលែងតែមានភ័ស្តុតាង *បឋម* (prima facie) ពីអំពើពុករលួយ ឬការលម្អៀងជាក់ស្តែង ដូចជាការចាប់បានចៅក្រម*កំពុងប្រព្រឹត្តបទល្មើសជាក់ស្តែង* ដោយការទទួលសំណូកសូកប៉ាន់ជាដើម។

១០ ការបកស្រាយវិធាន ៣៥ ដោយអង្គបុរេជំនុំជម្រះ ប្រសិនបើត្រូវបានទទួលយក ផ្តល់*អំណាចគ្មានដែនកំណត់ (carte blanche)* ដល់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តមិនសមស្រប ដោយកម្រិតយ៉ាងតឹងរឹងដោយមានប្រសិទ្ធិភាពចំពោះសិទ្ធិដាក់បណ្តឹងបន្ទាន់បង្ហំរបស់ភាគី។ វិធាន ៣៥ មិនអាចបកស្រាយដូច្នេះបានឡើយ។ វិធាន ២១ តម្រូវឲ្យបកស្រាយវិធានទាំងអស់ឲ្យការពារផលប្រយោជន៍របស់លោកអៀង សារី និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដែលជាលក្ខណៈពិសេសជាមូលដ្ឋានរបស់ អ.វ.ត.ក ដូចមានចែងក្នុងវិធាន ២១[15]។

---

[14] *មានន័យថា* ក្នុងករណី និងនៅពេលដែលចៅក្រមមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចបង្កើតឲ្យមានភាពលំអៀង *ប្រៀបធៀប* សាលដីកាសម្រេចលើចៅក្រម *Lemonde* កថាខណ្ឌ ១១

[15] វិធាន ២១ (១) ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។"

១១ អង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន ២១ “តម្រូវថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ ជនត្រូវចោទក្នុងការប្ដឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់ សេចក្ដីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ[16]”។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូល គប្បីអនុវត្តការបកស្រាយបែបទូលាយអំពីសិទ្ធិក្នុងការប្ដឹងសាទុក្ខភ្លាមៗ។ ការបកស្រាយបែបនេះជាការសំខាន់ណាស់នៅក្នុងរឿងក្ដីបច្ចុប្បន្ននេះដោយសារអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានគាំពារសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការកាត់សេចក្ដីដោយត្រឹមត្រូវ៖ ក) ការចូលរួម និងជួយការពារក្ដីរបស់គាត់ ខ) សិទ្ធិលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ គ) សិទ្ធិកាត់ទោសដោយផ្អែកលើច្បាប់ និង ឃ) សិទ្ធិមិនត្រូវបានដាក់ឱ្យនៅក្រោមវិធានការបង្ខំ ដែលមិនកម្រិតតឹងរឹងបំផុតសម្រាប់តែតម្រូវការចាំបាច់នៃដំណើរការនីតិវិធី និងមិនគោរពឱ្យបានពេញលេញនូវសេចក្ដីថ្លៃថ្នូរជាមនុស្សរបស់គាត់។

១២ វិធាន ៣៥ អនុវត្តបានចំពោះ “ជន*ណាម្នាក់*” ដែលជ្រៀតជ្រែកដោយចេតនា និងដឹងជាមុន ទៅក្នុងកិច្ចការរដ្ឋបាលតុលាការ[១៧]។ វិធាន ៣៥(១) មានរៀបរាប់អំពីបញ្ជីសកម្មភាពមិនលម្អិតមួយ ដែល

---

[16] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៣។

[១៧] វិធាន ៣៥ (១) ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា “អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែល...” (បញ្ជាក់បន្ថែម)។ នៅតុលាការ ICTY, វិធាន ៧៧(ក) នៃវិធាននីតវិធី និងភស្តុតាង ក៏ចែងរៀបរាប់ពីបញ្ជីសកម្មភាពយ៉ាងវែងដែលអាចជាការជ្រៀតទៅក្នុងកិច្ចការរដ្ឋបាលតុលាការដែរ។ “បញ្ជីនៃអំពើនានាដែលមានរៀបរាប់នៅក្នុងវិធាន ៧៧(ក) (i)-(v) នៃវិធាននេះមិនមែនកម្រិតតែប៉ុណ្ណឹងទេ ដែលត្រឹមតែបង្ហាញឧទាហរណ៍នៃអំពើនានាដែលជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ”។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Milošević*, សំណុំរឿងលេខ IT-02-54-Misc.5 និង IT-02-54-Misc.6, សេចក្ដីសម្រេចលើការផ្ដួចផ្ដើមឱ្យមានការស៊ើបអង្កេតទាក់ទិននឹងការប្រមាថតុលាការ, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ១១ *ដោយដកស្រង់ នៅក្នុងរឿងក្ដីប្រឆាំងនឹង Florence Hartman*, សំណុំរឿងលេខ IT-02-54-R77.5, សាលដីកាលើការចោទប្រកាន់ពីបទប្រមាថតុលាការ, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ ១៩; *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Aleksovski*, សំណុំរឿងលេខ IT-95-14/1-AR77, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ Anto Nobilo ប្រឆាំងនឹងសេចក្ដីសន្និដ្ឋានពីការប្រមាថតុលាការ, ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១, កថាខណ្ឌ ៣៩។

អាចបណ្តាលឲ្យជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ។ សហចៅក្រមស៊ើបអង្កេត បានបំភ្លឺថា នៅពេលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដូចមានចែងក្នុងវិធាន ៣៥ ដើម្បីដាក់ទណ្ឌកម្មចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការបាន គឺលុះតាតែ"កាតព្វកិច្ច និងការរំលោភបំពានលើកាតព្វកិច្ចនោះ ត្រូវបានរកឃើញជាមុនសិន"[១៨]។ អង្គជំនុំជម្រះសាលាដំបូងមានករណីយកិច្ចចំពោះជនជាប់ចោទគ្រប់គ្នា ក្នុងការធានាឲ្យបានថាកិច្ចដំណើរការនីតិវិធីតុលាការប្រព្រឹត្តទៅដោយអនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់[១៩] និងធានាឲ្យបាននូវការជំនុំជម្រះក្តី ដែលប្រព្រឹត្តទៅដោយមានការគោរពសិទ្ធិរបស់ជនជាប់ចោទ[២០]។ កាតព្វកិច្ចនោះនឹងត្រូវគេរំលោភបំពាន ដោយសារតែការជ្រៀតជ្រែករបស់អង្គជំនុំជម្រះសាលាដំបូងដោយដឹងច្បាស់ជាមុន និងដោយចេតនា ទៅក្នុង"កិច្ចការដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធទៅនឹងមុខងារនៃកិច្ចដំណើរការនីតិវិធីតុលាការនៅចំពោះមុខសាលាក្តី"[២១]។

១៣ ការដែលអង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យសុំលះបង់សិទ្ធិរបស់លោក អៀង សារី ដែលបានសុំលះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការ និងការចាប់បង្ខំគាត់ឲ្យមានវត្តមានគ្រប់ពេលក្នុងពេលសវនាការ ក្នុងខៈណៈពេលដែលគាត់គួរតែអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបានពីបន្ទប់រង់ចាំ អង្គជំនុំជម្រះសាលាដំបូងពិតជាបានរំលោភបំពានដោយដឹងច្បាស់ជាមុន និងដោយចេតនាលើកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារសិទ្ធិរបស់លោក អៀង សារី ជាសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធិជួយការពារក្តីរបស់គាត់ ព្រមទាំងសិទ្ធិលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ ដែលជាសិទ្ធិត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទណ្ឌកម្មលើលោក អៀង សារី ដូចជាគាត់កំពុងអនុវត្តទោសដែលបានកំណត់រួចហើយ។ ការបង្ខំឲ្យគាត់មានវត្តមានជានិច្ចនៅក្នុងសាលសវនាការ ខណៈពេលដែលគាត់ទទួលរងនូវការឈឺចាប់

---

[១៨] ដីកាស្តីពីសំណើរបស់ក្រុមសហមេធាវីការពារក្តីរបស់លោក អៀង សារី ស្នើសុំឲ្យដាក់ទណ្ឌកម្មលើសហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D97/9/7 កថាខណ្ឌ ៨

[១៩] កិច្ចព្រមព្រៀង មាត្រា ១២ (២)

[២០] ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា ២៣ ថ្មី។ *សូមមើលផងដែរ* វិធាន ២១

[២១] *ព្រះរាជអាជ្ញា ទល់នឹង Milošević*, IT-02-54-Misc.5 & IT-02-54-Misc.6 សេចក្តីសម្រេចស្តីពីការផ្តួចផ្តើមឲ្យមានកិច្ចស៊ើបអង្កេតមួយទាក់ទងនឹងការប្រមាថតុលាការ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

យ៉ាងដំណំ និងរងទុក្ខវេទនា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ទោសដោយខុសច្បាប់ ដែលជាការរំលោភបំពានដល់គោលការណ៍គ្មានទោសបើគ្មានច្បាប់ចែង (*nulla poena sine lege*) ដែលជាគោលការណ៍មានចែងយ៉ាងច្បាស់ក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៥(១) នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ ក៏រំលោភផងដែរលើវិធាន ២១(២) នៃវិធានផ្ទៃក្នុង ដែលបានហាមឃាត់វិធានការចាប់បង្ខំដែលមិនតឹងរឹងបំផុតសម្រាប់តែ តម្រូវការនៃកិច្ចដំណើរការនីតិវិធី និងដែលមិនបានគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

១៤ តាមការការចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយដឹងច្បាស់ជាមុន និងដោយចេតនា ដល់សិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ គឺសិទ្ធិទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវ។ ប្រសិនបើគ្មានអន្តរាគមន៍ភ្លាមៗពីអង្គជំនុំជម្រះតុលាការកំពូលនោះទេ អង្គជំនុំជម្រះសាលាដំបូងប្រហែលជានឹងបន្តជ្រៀតជ្រែកជាហូរហែរហូតចំពោះសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវដែលមានសារៈសំខាន់ចំពោះបណ្តឹងសាទុក្ខនៅគ្រប់ពេលក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។ ដើម្បីធានាឲ្យបានថា ទៅថ្ងៃអនាគត ពិតជាគ្មានការរំលោភបំពានណាមួយបន្ថែមទៀតទៅលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី អង្គជំនុំជម្រះតុលាការកំពូលគប្បីអនុវត្តយុត្តាធិការលើបណ្តឹងសាទុក្ខនេះ ហើយសេចក្តីសម្រេចដែលត្រូវបានជំទាស់ត្រូវសម្រេចថាជាការជ្រៀតជ្រែកដោយបានដឹងច្បាស់ និងដឹងជាមុន ចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខនេះអាចទទួលយកបានជាបណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤ (៤) (ឃ)។

## ខ) សំណើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ

១៥ ក្រុមសហមេធាវីការពារក្តីស្នើសុំឲ្យមានសវនាការសាធារណៈ ដោយផ្ទាល់មាត់ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខនេះ។ វិធាន ១០៩(១) ចែងថា សវនាការលើ

បណ្ដឹងសាទុក្ខ ត្រូវធ្វើឡើងជាសាធារណៈ[២២]។ បណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងរដ្ឋបាលតុលាការ។ បញ្ហាដែលមានលើកឡើងក្នុងបណ្ដឹងសាទុក្ខនេះ មិនមែនជាបញ្ហាសម្ងាត់នោះទេ។

## IV. សាវតារ

១៦ នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការជាសម្ងាត់ លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ថ្លែងថា បន្ទាប់ពីការធ្វើវិសោធនកម្មវិធាន ៨១ (៥) នៅក្នុងកិច្ចប្រជុំពេញអង្គក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ ជនជាប់ចោទអាចជ្រើសរើសចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈការភ្ជាប់បណ្ដាញវីដេអូ បានគ្រប់ពេល ក្នុងករណីមិនមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ លោក និល ណុន បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្ដីបង្គាប់បន្ថែមឲ្យជនជាប់ចូលរួមតាមរយៈការភ្ជាប់បណ្ដាញវីដេអូ ក្នុងករណីដែលតម្រូវឲ្យមានផលប្រយោជន៍នៃយុត្តិធម៌[២៣]។

១៧ នៅព្រឹកថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ នៅក្នុងសវនាការបឋម លោក នួន ជា បានស្នើសុំ "អនុញ្ញាតចាកចេញពីសាលសវនាការ និងខ្ញុំនឹង...ត្រឡប់មកវិញប្រសិនបើចៅក្រមពិចារណាសំណើរបស់ខ្ញុំ ដែលត្រូវដាក់ពិភាក្សាដេញដោលគ្នានៅចំពោះមុខសាធារណជន ក្នុងសវនាការសាធារណៈ"[២៤]។ ចៅក្រមប្រធាន និល ណុន ព្រមតាមសំណើនោះ ហើយលោក នួន ជា ត្រូវបាននាំទៅមន្ទីរឃុំឃាំងវិញ[២៥]។ ចៅក្រមប្រធាន និល ណុន គូសបញ្ជាក់ថា៖ "អង្គជំនុំជម្រះសូមជម្រាបភាគីឲ្យបានជ្រាបថា បន្ទប់រង់ចាំទាំងអស់ដែលស្ថិតនៅក្រោមសាលសវនាការនេះ ត្រូវបាន

---

[២២] វិធាន ១០៩(១) ចែងថា៖ "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូល អាចធ្វើសេចក្ដីសម្រេចពិចារណាលើបណ្ដឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

[២៣] ប្រតិចារឹកកិច្ចប្រជុំរៀបចំសវនាការ (សម្ងាត់) ថ្ងៃទី៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E1/1.2 (ប្រតិចារឹកកិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ២១-២២។ សូមមើលផងដែរ ដូចជើងទំព័រខាងលើ ទំព័រ ២៧-៤២

[២៤] ប្រតិចារឹកនៃសវនាការបឋម ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ទំព័រទី ១៧-១៨។

[២៥] ដូចខាងលើ ទំពីរទី ១៨។

បំពាក់ប្រព័ន្ធសោតទស្សន៍ និងខ្សែទូរស័ព្ទដែលអាចទាក់ទងគ្នាដោយផ្ទាល់រវាងបន្ទប់រង់ចាំនីមួយៗ និងសាលសវនាការ។ ក្នុងពេលណាក៏បានក្នុងកិច្ចដំណើរការសវនានេះ ជនជាប់ចោទអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍នេះបាន ដោយមិនបាច់មានវត្តមានដោយផ្ទាល់នៅក្នុងសាលសវនាការ"[២៦]។

១៨ នៅព្រឹកថ្ងៃដដែល លោក ផាត់ ពៅស៊ាង សហមេធាវីជាតិរបស់លោកស្រី អៀង ធីរិទ្ធ បានស្នើថា៖ "ដោយសារបញ្ហាសុខភាពរបស់កូនក្តីខ្ញុំ ខ្ញុំសូមការអនុញ្ញាតដើម្បីឲ្យគាត់អាចត្រលប់ទៅកាន់មន្ទីរឃុំឃាំងវិញ។ ដោយសារបញ្ហាសុខភាពនេះ គាត់នឹងមិនត្រឡប់មកកាន់សាលសវនាការរហូតដល់ចប់សវនាការបឋម"[២៧]។ ចៅក្រមប្រធាន និល ណុន បានយល់ព្រមតាមសំណើ និងលោកស្រី អៀង ធីរិទ្ធ ត្រូវបានបង្គាប់ឲ្យនាំខ្លួនត្រឡប់ទៅមន្ទីរឃុំឃាំងវិញ[២៨]។ ដោយអនុញ្ញាតឲ្យលោកស្រី អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញដូច្នេះ គឺលោកចៅក្រមប្រធាន និល ណុន បានទទួលស្គាល់"សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួម ឬមិនចូលរួមក្នុងសវនាការនេះ"[២៩]។ គាត់ក៏បានបង្គាប់ឲ្យភ្ជាប់ឧបករណ៍សោតទស្សន៍ ភ្ជាប់មកសាលសវនាការ ដើម្បីឲ្យលោកស្រី អៀង ធីរិទ្ធ អាចតាមដានកិច្ចដំណើការនីតិវិធីពីមន្ទីរឃុំឃាំងបាន[៣០]។

១៩ នៅរសៀលថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ លោកចៅក្រមប្រធាន និល ណុន បានគូសបញ្ជាក់ថា "មុននឹងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៅរសៀលនេះ អង្គជំនុំជម្រះសូមជម្រាបជនជាប់ចោទ និងក្រុមសហមេធាវីរបស់គាត់ឲ្យបានជ្រាបថា អនុលោមតាមវិធាន ៨១(៣) (៤) និង (៥) ជនជាប់ចោទតម្រូវឲ្យមានវត្តមានក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនេះ"[៣១]។ ជាងនេះ

---

[២៦] ដូចខាងលើ ទំព័រទី ៣៣-៣៤។

[២៧] ដូចខាងលើ ទំព័រទី ៣៨។

[២៨] ដូចខាងលើ ទំព័រទី ៣៩។

[២៩] ដូចខាងលើ។

[៣០] ដូចខាងលើ។

[៣១] ដូចខាងលើ ទំព័រទី ៦២។

ទៅទៀត"នៅរៀងរាល់ថ្ងៃសវនាការ ជនជាប់ចោទត្រូវតែមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះជាមុនសិន មុននឹងបង្ហាញមូលហេតុដែលនាំឲ្យមានការស្នើសុំចាកចេញពីសាលសវនាការ"[៣២]។ លោកចៅក្រមប្រធាន និល ណុន ក៏បានគូសបញ្ជាក់ថា "ឧបករណ៍សោតទស្សន៍ត្រូវបានរៀបចំរួចជាស្រេច ដើម្បីឲ្យជនជាប់ចោទអាចតាមដានកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយចូលរួមពីចម្ងាយបានផងដែរ"[៣៣]។

២០ ក្រោយពីលោកចៅក្រមប្រធាន និល ណុន មានប្រសាសន៍រួច លោក ស សូវាន សហមេធាវីជាតិរបស់លោក ខៀវ សំផន បានថ្លែងថា៖

> នៅក្នុងអំឡុងពេលនៃសវនាការនេះ កូនក្តីរបស់ខ្ញុំមានការនឿយហត់ និងខ្សោយកម្លាំង។ ដូច្នេះ យើងខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីឲ្យគាត់បានទៅបន្ទប់រង់ចាំនៅខាងក្រោម។ គាត់នឹងវិលត្រឡប់មកកាន់សាលសវនាការវិញនៅថ្ងៃស្អែក។ គាត់ប្រាប់ខ្ញុំថា ឥឡូវនេះ គាត់អាចអនុញ្ញាតឲ្យខ្ញុំតំណាងការពារក្តីឲ្យគាត់នៅក្នុងសាលសវនាការនេះបាន និងថា កិច្ចដំណើរការក្នុងសាលសវនាការថ្ងៃនេះ គឺដើម្បីតែក្រុមមេធាវីការពារក្តីដទៃទៀតប៉ុណ្ណោះ គឺមិនពាក់ព័ន្ធនឹងរូបគាត់នោះទេ ដូច្នេះគាត់សុំសម្រាកដើម្បីយកកម្លាំងទុកសម្រាប់វគ្គសវនាការនៅថ្ងៃស្អែកវិញ[៣៤]។

២១ លោកចៅក្រមប្រធាន និល ណុន បានឆ្លើយតបទៅនឹងសំណើនោះដូច្នេះថា៖

> អង្គជំនុំជម្រះបានកត់សម្គាល់សំណើនោះ... និងបានកត់សម្គាល់មូលហេតុនៃសំណើ។ អង្គជំនុំជម្រះក៏កត់សម្គាល់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ លោក ខៀវ សំផន មើលទៅមិនទំនងជាមានសុខភាពខ្សោយ ឬបញ្ហាធ្ងន់ធ្ងរនោះទេ។ ដូច្នេះហើយទើប

---

[៣២] ដូចខាងលើ ទំព័រទី ៦៣។

[៣៣] ដូចខាងលើ។

[៣៤] ដូចខាងលើ ទំព័រ ៦៤។

អង្គជំនុំជម្រះយល់ឃើញថា គាត់ត្រូវមានវត្តមានតទៅទៀតនៅក្នុងសាលសវនាការនេះ[៣៥]។

២២ លោក Michael G. Karnavas សហមេធាវីអន្តរជាតិរបស់លោក អៀង សារី បានលើកឡើងថា៖

ជាបឋម ខ្ញុំសូមគោរពលោកប្រធាន ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ខ្ញុំយល់ឃើញថា នៅពេលណាជនជាប់ចោទ គិតថាខ្លួនគាត់មិនអាចមានវត្តមាននៅក្នុងសាលសវនាការបាន និងមានបំណងសុំលះបង់សិទ្ធិមានវត្តមាននេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុញ្ញាត។

...

យើងខ្ញុំសូមស្នើដោយក្តីគោរពថា អង្គជំនុំជម្រះគប្បីពិចារណារឿងនេះឲ្យបានល្អិតល្អន់ជាងនេះ ដ្បិតពួកគាត់គឺសុទ្ធតែជាមនុស្សវ័យចាស់។ បើយើងមើលពួកគាត់តែរូបរាងខាងក្រៅ គឺយើងពុំឃើញមានអ្វីជាបញ្ហានោះទេ ប៉ុន្តែពិសេសកូនក្តីរបស់ខ្ញុំ គាត់មានបញ្ហាក្នុងការអង្គុយ។ គាត់មិនអាចអង្គុយបានយូរទេ។ ដូចយើងឃើញស្រាប់ហើយ កន្លះម៉ោងម្តងគាត់ក៏ត្រូវការទៅបន្ទប់ទឹក។ ការឲ្យគាត់នៅទីនេះដូច្នេះ គឺជាការឈឺចាប់ណាស់សម្រាប់គាត់។ គាត់មិនអាចផ្តង់អារម្មណ៍បាន។ មែនទែនទៅ គឺគាត់មិនអាចជួយការពារក្តីរបស់គាត់បានទេ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានសម្រេចអនុម័តនីតិវិធីមួយ ដែលខ្ញុំជឿថាជាការវិវឌ្ឍបែបទំនើបមួយផ្នែកច្បាប់ គឺការដែលបង្កើតឲ្យមានជាបន្ទប់រង់ចាំដែលនៅក្បែរនេះ ដើម្បីអាចឲ្យកូនក្តីចូលរួម និងមេធាវីអាចជួយកូនក្តីរបស់ខ្លួនបាន។

...

ការបង្ខំឲ្យជនជាប់ចោទមានវត្តមាន នៅពេលដែលគាត់មិនអាចមានវត្តមាន ឬមិនចង់មានវត្តមាននៅទីនេះ គឺមិនមែនជាដំណោះស្រាយមួយនោះទេ។ ដូចខ្ញុំបានជម្រាបបញ្ជាក់រួចហើយ ប្រសិនបើជនជាប់ចោទណាម្នាក់ គ្មានបំណងចូលរួម ឬអាចដោយសារមូលហេតុអ្វីក៏ដោយដែលជនជាប់ចោទជាអ្នកសម្រេចដោយខ្លួនឯង នោះអង្គជំនុំជម្រះមិនត្រូវដកហូតសិទ្ធិនេះពីគាត់បាននោះទេ។ ផ្ទុយទៅវិញ ការបង្ខំជនជាប់ចោទឲ្យមានវត្តមានក្នុង

[៣៥] ដូចខាងលើ។

សាលសវនាការ នៅពេលដែលបញ្ហាសុខភាពរាងកាយរបស់គាត់មិនអនុញ្ញាត ឬនៅពេលដែលសុខភាពផ្លូវចិត្តគាត់មិនអាចឲ្យគាត់មានវត្តមានក្នុងសាលសវនាការបាន ខ្ញុំសូមលើកឡើងដោយក្តីគោរពថា នេះគឺនាំឲ្យមានការរំលោភបំពានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិមនុស្សរបស់គាត់ហើយ។
...
ជម្រើសសម្រាប់ដោះស្រាយគឺមានតែអនុញ្ញាតឲ្យភាគីបញ្ចេញយោបល់ត្រួសៗទៅលើបញ្ហានេះតែប៉ុណ្ណោះ... ប៉ុន្តែ ខ្ញុំជឿថា បើកូនក្តីណាម្នាក់មិនចង់មានវត្តមានក្នុងសាលសវនាការ គេមិនអាចចាប់បង្ខំគាត់ឲ្យមានវត្តមានក្នុងសាលសវនាការបាននោះទេ។ ហើយប្រសិនបើគាត់មិនអាចមានវត្តមានក្នុងសាលសវនាការបាន គេមិនគប្បីចាប់បង្ខំឲ្យគាត់មានវត្តមាននោះទេ។ ហើយខ្ញុំជឿថា តាមទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំអាចស្រាវជ្រាវបន្ថែមទៀតក្នុងរឿងនេះ ប៉ុន្តែខ្ញុំនៅតែជឿថា ការបង្ខំឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ នៅពេលដែលគាត់បានសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់រួចហើយ មិនចំពោះគាត់ទទួលស្គាល់តុលាការ ឬមិនទទួលស្គាល់តុលាការនោះទេ គឺនៅពេលពួកគាត់លះបង់សិទ្ធិមានវត្តមានរបស់ពួកគាត់រួចហើយ ពាក្យលះបង់សិទ្ធិនោះគឺជាអ្វីដែលគាត់ធ្វើដោយស្ម័គ្រចិត្ត ដូច្នេះគេមិនអាចរំលោភបំពានលើសិទ្ធិរបស់ពួកគាត់បាននោះទេ។ ប៉ុន្តែ ខ្ញុំគិតថា ការចាប់បង្ខំឲ្យជនជាប់ចោទមានវត្តមានក្នុងសវនាការ គឺជាការរំលោភបំពានសិទ្ធិមនុស្ស គឺនៅពេលដែលស្ថានភាពរបស់គាត់បង្ហាញយ៉ាងច្បាស់ថាគាត់មិនអាចមានវត្តមាននៅទីនេះបាន[៣៦]។

២៣ លោក Andrew Cayley សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា "មានគោលការណ៍ជាមូលដ្ឋានមួយដែលតម្រូវថាជនជាប់ចោទត្រូវតែមានវត្តមានក្នុងពេលជំនុំជម្រះ"[៣៧]។ គាត់បន្តទៀតថា "ក្នុងករណីដែលជនជាប់ចោទ ពិតជាមិនអាចមានវត្តមានក្នុងសាលសវនាការក្នុងអំឡុងពេល

---

[៣៦] ដូចខាងលើ ទំព័រទី ៦៥-៦៧ ៦៩-៧០។

[៣៧] ដូចខាងលើ ទំព័រ ៧១។

នៃកិច្ចដំណើរការនីតិវិធីមែន ប្រសិនបើតុលាការត្រូវអនុញ្ញាតតាមសំណើនោះ តុលាការត្រូវតែដឹងឲ្យច្បាស់ជាមុនសិន ថាតើមូលហេតុអ្វីដែលនាំឲ្យបុគ្គលនោះមិនអាចមានវត្តមានបាន"[៣៨]។

២៤ លោកចៅក្រម Lavergne បានបញ្ជាក់ថា "ក្នុងករណីជនជាប់ចោទ បដិសេធមិនបង្ហាញខ្លួន គាត់អាចលះបង់សិទ្ធិក្នុងការមានវត្តមាននៅទីនេះ និងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីរបស់ខ្លួនធ្វើតំណាង ប៉ុន្តែត្រូវបង្ហាញចេតនាថាមិនបង្ហាញខ្លួន[៣៩]"។ លើសពីនេះទៅទៀត "អង្គជំនុំជម្រះសាលាដំបូង ចង់ដឹងមុនពេលចាប់ផ្តើមសវនាការជារៀងរាល់ថា...ប្រសិនបើជនជាប់ចោទណាមួយមានបំណងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ" អនុលោមតាមវិធាន៨១ (៤)[៤០]។ លោកចៅក្រម Lavergne បានបន្តថាអង្គជំនុំជម្រះសាលាដំបូង ត្រូវដឹងពីសុខភាព ឬបញ្ហាធ្ងន់ធ្ងរដទៃទៀតដែលជនជាប់ចោទមិនអាចបង្ហាញខ្លួន និងមានបំណងចូលរួមពីចម្ងាយ អនុលោមតាមវិធាន ៨១ (៥) [៤១]។

២៥ លោកស្រី Elisabeth Simoneau-Fort សហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា "ត្រូវគោរពសិទ្ធិទាំងអស់ តាមលទ្ធភាពអាចធ្វើបាន នេះជាបញ្ហានៃការគោរពសិទ្ធិជនរងគ្រោះ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី...ហើយបើអាចធ្វើបាន ពួកគាត់ចង់ឃើញជនជាប់ចោទមានវត្តមានក្នុងអំឡុងកិច្ចដំណើរការនីតិវិធីទាំងនេះ[៤២]។"

---

[៣៨] ដូចខាងលើ ទំព័រ ៧២។

[៣៩] ដូចជើងទំព័រខាងលើ លោកចៅក្រម Lavergne បានបញ្ជាក់ថាគាត់យោងលើវិធាន ៨១ (៤) នៅពេលគាត់ពិភាក្សាអំពីសិទ្ធិមិនបង្ហាញខ្លួនក្នុងសាលសវនាការ *សូមមើល* ជើងទំព័រខាងលើទំព័រ ៧៦។

[៤០] ដូចជើងទំព័រខាងលើ ទំព័រ ៧៥

[៤១] ដូចជើងទំព័រខាងលើ

[៤២] ដូចជើងទំព័រខាងលើ ទំព័រ ៧៨

២៦ បន្ទាប់ពីបានពិភាក្សា និងជាការឆ្លើយតបទៅនឹងសុំណើសុំចាកចេញពីសាលសវនាការរបស់លោក អៀង សារី លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា "ការបង្ហាញនូវមូលហេតុ និងស្ថានភាពជំងឺ និងសុខភាពរបស់ជនជាប់ចោទរូបនោះ មានបញ្ហាពិតប្រាកដដែលអាចឲ្យតុលាការជឿបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះ យល់ព្រមអនុញ្ញាតឲ្យលោក អៀង សារី ទៅសម្រាកនៅក្នុងបន្ទប់ខាងក្រោមដែលបានរៀបចំរួចជាស្រេចសម្រាប់ដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍[៤៣]"។ ប្រធានអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់បន្ថែមទៀតថា "អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីម្តងទៀតថា ចំពោះជនជាប់ចោទទាំងអស់ អង្គជំនុំជម្រះ តម្រូវឲ្យអនុរក្សមន្ទីរឃុំឃាំងនាំមកបន្ទប់សវនការជារៀងរាល់ព្រឹកសម្រាប់ថ្ងៃនីមួយៗ។ ចំណែកឯបញ្ហាៗផ្សេងៗដែលអាចកើតឡើងក្នុងថ្ងៃនីមួយៗនោះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើសំណើជាក់ស្តែងករណីនីមួយៗ នឹងសម្រេចតាមទៅស្ថានភាពជាក់ស្តែងថាតើអនុញ្ញាត ឬមិនអនុញ្ញាត[៤៤]"។

២៧ កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ លោក នួន ជា បានស្នើសុំត្រឡប់មកបន្ទប់ឃុំឃាំងវិញ ដោយសារកិច្ចដំណើរការនីតិវិធី មិនទាក់ទងនឹងគាត់[៤៥]។ ប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន បានផ្តល់ការអនុញ្ញាតឲ្យគាត់ត្រឡប់ទៅមន្ទីរឃុំឃាំងគាត់វិញ ដោយបញ្ជាក់ថា "នេះជាសិទ្ធិរបស់ជនជាប់ចោទ...អនុញ្ញាតឲ្យលោកដកខ្លួនថយចេញពីដំណើរការសវនាការនេះទៅកាន់មន្ទីរឃុំឃាំងវិញ[៤៦]"។ បន្ទាប់មកទៀត មេធាវីជាតិការពារក្តីលោកស្រី អៀង ធីរិទ្ធ សុំអនុញ្ញាតឲ្យកូនក្តី "ទៅមន្ទីរឃុំឃាំងវិញដោយសារគាត់មិនស្រួលក្នុងខ្លួន[៤៧]"។ លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឲ្យគាត់ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ "ដោយសារមានមូលហេតុ

---

[៤៣] ដូចជើងទំព័រខាងលើ ទំព័រ ៧៨-៧៩

[៤៤] ដូចជើងទំព័រខាងលើ ទំព័រ ៧៩

[៤៥] ប្រតិចារឹកសវនាការបឋម ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/5.1 ទំព័រ ១-២

[៤៦] ដូចជើងទំព័រខាងលើ ទំព័រ ២

[៤៧] ដូចជើងទំព័រខាងលើ ទំព័រ ៨៣

សមស្រប" ហើយក៏បានអនុញ្ញាតឲ្យលោកអៀង សារី ត្រឡប់មកមន្ទីរឃុំឃាំងវិញ "សភាពរូបរាងកាយរបស់គាត់គឺមានស្ថានភាពមានបញ្ហា ហើយម្យ៉ាងទៀតជនជាប់ចោទអៀង សារី បានអង្គុយយូរក្នុងសាលសវនាការនេះ[៤៨]"។

២៨ កាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី បានដាក់ការកត់សម្គាល់របស់ខ្លួន។ ការកត់សម្គាល់នេះត្រូវបានដាក់ដើម្បីបញ្ជាក់ថា នៅក្នុងកម្រិតអន្តរជាតិ ជនជាប់ចោទមានសិទ្ធិបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការ ក្នុងករណីគាត់ធ្វើដោយដោយស្ម័គ្រចិត្ត ដោយដឹងច្បាស់ និងដោយឥតមន្ទិលសង្ស័យ ហើយគាត់តំណាងដោយមេធាវីការពារ។ ការកត់សម្គាល់នេះត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងជួយអង្គជំនុំជម្រះសាលាដំបូង។

២៩ កាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា បានឆ្លើយតបទៅនឹងការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី ដោយបានលើកឡើងថា៖

> វត្តមានផ្ទាល់របស់ជនជាប់ចោទនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ ជាកាតព្វកិច្ចមួយក្រោមច្បាប់កម្ពុជាដែលស្របគ្នានឹងបទដ្ឋានអន្តរជាតិ ដោយមានការលើកលែងជាក់លាក់ខ្លះប៉ុណ្ណោះ។ ទន្ទឹមនេះ អៀង សារី មានកាតព្វកិច្ចផ្លូវច្បាប់ចូលរួមដោយផ្ទាល់ដោយខ្លួនឯងក្នុងកិច្ចដំណើរការនីតិវិធីសវនាការ។...អង្គជំនុំជម្រះអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនបង្គាប់ឲ្យ អៀងសារី ត្រូវបង្ហាញវត្តមានដោយផ្ទាល់នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែ ការប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីចាប់បង្ខំវត្តមានរបស់គាត់នៅក្នុងស្ថានភាពមួយ ដែលមានការបដិសេធជាបន្តបន្ទាប់ដើម្បីចូលរួមដោយផ្ទាល់ អាចកម្រិតក្នុងលក្ខណៈមួយដែលមិនមានសមាមាត្រនឹងគ្នាដល់សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវសេចក្តីថ្លៃថ្នូររបស់គាត់។...អង្គជំនុំជម្រះអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បី

[៤៨] ដូចជើងទំព័រខាងលើ ទំព័រ ៨៤

ទទួលយកការលះបង់សិទ្ធិធ្វើឡើងជាលាយលក្ខណ៍អក្សរដោយជនជាប់ចោទ ក្នុងការមានវត្តមានដោយផ្ទាល់នៅក្នុងដំណើរការនីតិវិធីសវនាការ ប៉ុន្តែអាចធ្វើដូច្នេះបានលុះត្រាតែ៖

(ក) ជាដំបូង បានធ្វើការថ្លឹងថ្លែងអំពីកាតព្វកិច្ចត្រូវបានវត្តមានដោយផ្ទាល់ និងផលប្រយោជន៍ផ្នែកច្បាប់ដទៃទៀតដែលពាក់ព័ន្ធ ដើម្បីកំណត់សម្រេចថាតើការបោះបង់សិទ្ធិនោះគឺពិតជាផលប្រយោជន៍នៃយុត្តិធម៌ទេ។

(ខ) លើកលែងតែជនជាប់ចោទបានបំពេញកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងមានមូលហេតុគ្រប់គ្រាន់ជាយុត្តិកម្មសម្រាប់អវត្តមានរបស់គាត់ពីកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនីមួយៗនៃកិច្ចដំណើរការនីតិវិធី ដែលអាចរាប់បញ្ចូលទាំង ការបដិសេធមិនចូលរួមរបស់គាត់។ និង

(គ) ជនជាប់ចោទអាចទទួលការព្រមានដោយផ្ទាល់ថា អង្គជំនុំជម្រះរំពឹងទុកថា ជនជាប់ចោទនឹងចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងថាអវត្តមានរបស់ខ្លួនពីសវនាការជំនុំជម្រះក្រោយមកនឹងមិនមែនជាទឡ្ហីករណ៍សម្រាប់បណ្តឹងសាទុក្ខទេ[៤៥]។

៣០ កាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានថ្លែងក្នុងអំឡុងសវនាការស្តីពីសម្បទារបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការថា៖

ដើម្បីជាប្រយោជន៍ដល់ភាគី និងសាធារណជន ជនជាប់ចោទទាំងអស់ រួមទាំង លោក អៀង សារី ផង នឹងត្រូវកោះហៅឱ្យចូលខ្លួន និងត្រូវនាំខ្លួនមកតុលាការ នៅមុនពេល

---

[៤៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការកត់សម្គាល់របស់ អៀង សារី ស្តីអំពីថាតើអង្គជំនុំជម្រះសាលាដំបូង អាចចាប់បង្ខំជនជាប់ចោទឱ្យមានវត្តមានក្នុងតុលាការដែរឬទេ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E130/2 កថាខណ្ឌ ២។

**បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលជំនុំជម្រះក្តី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់**

ចាប់ផ្ដើមសវនាការនីមួយៗ។ ពេលមកដល់នៅចំពោះមុខអង្គជំនុំជម្រះ ជនជាប់ចោទ អៀង សារី មានសិទ្ធិលះបង់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងសវនាការ ហើយគាត់មិនអាចត្រូវបានបង្ខំឲ្យស្ថិតនៅក្នុងសាលសវនាការទេ[៥០]។

៣១ កាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ចេញអនុស្សរណៈផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង០០២ បញ្ជាក់ពីការកត់សម្គាល់របស់លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១១ និងបញ្ជាក់បន្ថែមទៀតថា៖

> អង្គជំនុំជម្រះនឹង ... កោះហៅជនជាប់ចោទទាំងអស់ឲ្យមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅមុនពេលចាប់ផ្ដើមសវនាការក្នុងថ្ងៃនីមួយៗនៃសំណុំរឿងលេខ ០០២។
>
> នៅពេលជនជាប់ចោទណាម្នាក់បោះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ជនជាប់ចោទរូបនោះអាចត្រឡប់ទៅបន្ទប់រង់ចាំស្ថិតនៅក្រោមបន្ទប់សវនាការដែលមានឧបករណ៍សោតទស្សន៍សម្រួលដល់ការទំនាក់ទំនងជាមួយក្រុមមេធាវីការពារក្ដីរបស់ខ្លួន និងចូលរួមកិច្ចដំណើរការនីតិវិធីបាន។ នៅគ្រប់ករណីបែបនេះ ក្រុមមេធាវីការពារក្ដីត្រូវប្រគល់ជូនអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការ ដោយមានហត្ថលេខាយ៉ាងច្បាស់របស់ជនជាប់ចោទ។
>
> អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ប្រសិនបើអង្គជំនុំជម្រះយល់ថាចាំបាច់ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ ដើម្បីការពារ

---

[៥០] ប្រតិចារឹកសវនាការបឋម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/2.1 ទំព័រ ១៣៦-១៣៧

នូវសិទ្ធិរបស់ជនជាប់ចោទ ឬមួយវត្តមានរបស់ជនជាប់ចោទមានសារៈសំខាន់ធ្វើឲ្យសវនាការប្រព្រឹត្តទៅដោយប្រសិទ្ធិភាព[៥១]។

៣២ កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងអំឡុងពេលធ្វើសេចក្ដីសន្និដ្ឋានបើក លោកអាង ឧត្ដម មេធាវីជាតិការពារលោក អៀង សារី ស្នើថា "ដោយសារលោក អៀង សារី មានបញ្ហាឈឺចង្កេះ ផ្អឹងខ្នងទ្រាំទ្រអង្គុយនៅទីនេះលែងបាន អញ្ជើងសូមលោកប្រធានមេត្ដាអនុញ្ញាតឲ្យគាត់ចុះទៅតាមដានសវនាការនៅក្នុងបន្ទប់ខាងក្រោម។ ហើយខ្ញុំបានសូមអនុញ្ញាតនេះគឺមួយថ្ងៃពេញតែម្ដងសម្រាប់ថ្ងៃរសៀលនេះដែរ[៥២]។" លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបថា៖

> អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាបញ្ហានៃសវនាការនៅពេលនេះគឺការធ្វើសេចក្ដីសន្និដ្ឋានសង្ខេបពីបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ហើយដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ វត្តមានរបស់ជនជាប់ចោទនាពេលនេះ មានសារៈសំខាន់ធ្វើឲ្យសវនាការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព។ ម្យ៉ាងទៀតដើម្បីបង្ហាញភាគី និងសាធារណៈជនឲ្យដឹងច្បាស់ ជនជាប់ចោទពិតជាបានស្ដាប់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួនពិតប្រាកដមែន។ ហេតុដូច្នេះ អង្គជំនុំជម្រះ បដិសេធនូវសំណើរបស់ជនជាប់ចោទ ដែលស្នើមិនចូលរួមដោយផ្ទាល់នៅក្នុងសវនាការនេះដោយមានបំណងទៅបន្ដដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍[៥៣]។

៣៣ កាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Michael G. Karnavas បានថ្លែងថា៖

---

[៥១] អនុស្សរណៈរបស់លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងក្នុងសំណុំរឿង ០០២ ៖ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹង "ការកត់សម្គាល់" របស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ លេខ E130/3) ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង")

[៥២] ប្រតិចារឹកនៃសេចក្ដីសន្និដ្ឋានបើក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13.1 ទំព័រ ៣៦

[៥៣] ដូចជើងទំព័រខាងលើ

សូមអធ្យាស្រ័យ លោកប្រធាន លោក លោកស្រីចៅក្រម។ ពីម្សិលមិញគឺថាសូមលើកពីម្សិលមិញម្តងហើយ ថ្ងៃនេះម្តងទៀត ដែលថាកូនក្តីរបស់ខ្ញុំមានការព្រួយបារម្ភដែលថា រំលោភទៅដល់សិទ្ធិមនុស្ស សិទ្ធិរបស់គាត់ដោយបង្ខំគាត់ឲ្យចូលរួមនៅក្នុងសវនាការនេះ គាត់ឈឺក្បាលពេលមួយរសៀលពីម្សិលមិញ គាត់ដោះប្រដាប់ស្តាប់ចេញ គាត់មិនអាចស្តាប់ គាត់មានការឈឺចាប់ គាត់បានសុំបោះបង់សិទ្ធិមានវត្តមាន ប៉ុន្តែលោកនៅបង្ខំឲ្យគាត់នៅទីនេះ ដោយអះអាងថាវាជាផ្នែកដ៏សំខាន់ដែលមិនអាចខ្វះបាននៃដំណើរការនីតិវិធី។

សេចក្តីសន្និដ្ឋានបើក មិនមែនជាភស្តុតាងឡើយ មិនដែល ហើយនឹងមិនត្រូវបានអនុវត្តជាការបង្ហាញភស្តុតាងឡើយ ប៉ុន្តែប្រហែលជាគ្រាន់តែសេចក្តីថ្លែងការបើកដែលជាការដើរតួសម្តែងតែប៉ុណ្ណោះ។ ដូច្នេះវាមិនមែនជាផ្នែកសំខាន់ដែលមិនអាចខ្វះបាននៃកិច្ចដំណើរការនីតិវិធីឡើយ ហើយអ្វីដែលមិនអាចខ្វះបានគឺសិទ្ធិរបស់ជនជាប់ចោទទាំងអស់ក៏ដូចជាសិទ្ធិរបស់ភាគីទាំងអស់ដូច្នេះដែរ។

> លោក អៀង សារី មានបំណងចូលរួម ប៉ុន្តែគាត់មិនអាចចូលរួមបាន ប្រសិនណាគាត់មិនអាចស្តាប់បានអំពីដំណើរការនីតិវិធី គាត់សូមទៅស្តាប់នៅជាន់ខាងក្រោម។
>
> គាត់មានឆន្ទៈធ្វើដូច្នេះ ប៉ុន្តែគាត់ត្រូវបានបង្ខំឲ្យនៅទីនេះ ហើយគាត់បានយកកាសស្តាប់ចេញពីត្រចៀករបស់គាត់។ បើគាត់ស្តាប់មិនបាន ហើយបង្ខំឲ្យគាត់ធ្វើដូច្នេះ នោះជាការបង្ខំឲ្យគាត់ចូលរួមនៅក្នុងសវនាការមួយ ដែលជាសវនាការដោយបង្ខំ និងសវនាការដែលគួរឲ្យអៀនខ្មាស់។ វត្តមានរបស់គាត់នៅទីនេះក្លាយទៅជាការចំអក គាត់មិនអាចចូលរួម ហើយគាត់មិនអាចណែនាំទៅមេធាវីគាត់ទេ។

ដូច្នេះ ខ្ញុំសូមសំណូមពរដល់លោកប្រធានជាមួយសហការីរបស់ខ្ញុំនេះ គឺសូមឲ្យសម្រេចទៅលើបញ្ហានេះឈានទៅដល់ការសម្រេចមួយ ដោយថាបើធ្វើដូច្នេះវាចោទបញ្ហាដែលបន្តទៅទៀត។ បើសិនជាលោកចង់ឲ្យពិភពលោកមើលថាតុលាការនេះជាតុលាការគំរូ ហើយថាតុលាការនឹងនាំមកនូវយុត្តិធម៌ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញ ដោយលើកឡើងពីពាក្យរបស់ ជែកសាន់ ខ្ញុំសូមសំណូមពរថាយើងប្រឹងប្រែងឲ្យដំណើរការនីតិវិធីដំណើរការទៅបានរលូន និងធ្វើឲ្យជនជាប់ចោទអាចចូលរួមក្នុងការការពារក្តី។ មិនមានសវនាការអន្តរជាតិនៅតុលាការអន្តរជាតិណាមួយដែលបង្ខំឲ្យជនជាប់ចោទត្រូវមានវត្តមាននៅក្នុងសាលសវនាការនោះទេ ដូចជាតុលាការនៅអតីតយូហ្គោស្លាវីរវ៉ាន់ដាតុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ឡេបាណន់ ឬក៏ដោយតុលាការអាយ.ស៊ី.ស៊ី។

យើងធ្វើការកត់សម្គាល់ដោយសារយើងមានការព្រួយបារម្ភថា ចៅក្រមខ្លះមិនបានដឹងឲ្យច្បាស់ ឬយកចិត្តទុកដាក់ចំពោះសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌សម្រាប់ជនជាប់ចោទនោះ ដោយសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងនោះគឺការលះបង់សិទ្ធិមានវត្តមាន ដូច្នេះហើយបានជាយើងស្នើដូច្នេះនោះ។

ហេតុដូច្នេះ បានយើងខ្ញុំសំណើទទូចសុំទៅដល់លោកប្រធានដោយក្តីគោរពបំផុតថាសូមឲ្យលោកប្រធានមេត្តាពិចារណា ឬក៏ពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឲ្យគាត់ចុះទៅជាន់ក្រោមសម្រាកស្តាប់ដំណើរការនីតិវិធី ដើម្បីឲ្យគាត់អាចណែនាំ និងប្រាប់មេធាវីរបស់គាត់។ គាត់មិនមែនដកខ្លួនពីកិច្ចដំណើរការនីតិវិធីទេ គាត់ចូលរួម ហើយគាត់មានបំណងចូលរួម។ សូមអនុញ្ញាតគាត់ឲ្យចូលរួម ដោយធានាទៅដល់ការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់[៥៤]។

---

[៥៤] ប្រតិចារឹកនៃសេចក្តីសន្និដ្ឋានបើក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/14.1 ទំព័រ ១-៣ (គូសបញ្ជាក់បន្ថែម)

៣៤ លោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា៖

> អង្គជំនុំជម្រះយល់ឃើញថា បញ្ហាដំណើរការសវនាការនាពេលនេះ គឺជាការធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងដើម្បីបង្ហាញដល់ភាគី និងសាធារណៈជនទាំងអស់ឲ្យបានដឹងកាន់តែច្បាស់ថាជនជាប់ចោទពិតជាបានស្តាប់ និងបានដឹងនូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួនគាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំរបស់ជនចាប់ចោទតម្រូវឲ្យជនជាប់ចោទនៅក្នុងសាលសវនាការនោះ ដើម្បីតាមដានសវនាការជាបន្ត[៥៥]។

## V. ឧបករណ៍ និងច្បាប់

៣៥ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀម តម្រូវឲ្យអនុវត្តកិច្ចដំណើរការនីតិវិធីស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់[៥៦]។ អង្គជំនុំជម្រះសាលាដំបូង ត្រូវធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងត្រូវការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់លោក អៀង សារី[៥៧]។ ដូចបានបង្ហាញនៅខាងលើ សិទ្ធិទាំងនេះរួមមាន សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធទទួលបានជំនួយសម្រាប់ការការពារក្តី និងសិទ្ធិក្នុងការបោះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការ។ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងកិច្ចព្រមព្រៀង ក៏មានដាក់បញ្ចូលគោលការណ៍មិន

[៥៥] ដូចជើងទំព័រខាងលើ ទំព័រ៨

[៥៦] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងមាត្រា ១៣ (១) នៃកិច្ចព្រមព្រៀង

[៥៧] មាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត មាត្រា ១៣ នៃកិច្ចព្រមព្រៀង វិធាន ២១នៃវិធានផ្ទៃក្នុង

មានទោសប្រសិនបើគ្មានច្បាប់ចែង (*nulla poena sine leg*) ផងដែរ[៥៨]។ យោងតាមគោលការណ៍នេះ លោកអៀង សារី អាចរងនូវទណ្ឌកម្មតាមផ្លូវច្បាប់ ដែលមានចែងក្នុងច្បាប់តែប៉ុណ្ណោះ[៥៩]។ វិធាន ២១ (២) ក៏ចែងថា "វិធានការចាប់បង្ខំទាំងឡាយណា ចំពោះបុគ្គលណាម្នាក់ [លោក អៀង សារី] ត្រូវ...ត្រូវតែកម្រិតតឹងរឹងបំផុតសម្រាប់តែ តម្រូវការនៃដំណើរការនីតិវិធី ដោយសមមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិឲ្យមានពេញលេញ"។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើកាតព្វកិច្ចទាំងនេះ និងបានរំលោភលើសិទ្ធរបស់លោកអៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដោយបានធ្វើឲ្យគាត់មានការឈឺចាប់ផ្នែករាងកាយដោយមិនមានសំអាងហេតុសមស្រប ដែលអាចនិយាយបានជាការការដាក់ទណ្ឌកម្មលើរូបគាត់ និងមិនយកចិត្តទុកដាក់ពីការបោះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការរបស់គាត់ និងបង្ខំឲ្យគាត់បន្តនៅក្នុងបន្ទប់សវនាការ ក្នុងពេលដែលគាត់ឈឺចាប់ខ្លាំងរាងកាយ និងមិនស្រួលខ្លួន ជាជាងអនុញ្ញាតឲ្យគាត់ចូលរួមក្នុងដំណើរការនីតិវិធីពីបន្ទប់រង់ចាំដែលមានរៀបចំឧបករណ៍សោតទស្សន៍។

---

[៥៨] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៣៣ ថ្មីនៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក និងមាត្រា ១៣ (១) នៃកិច្ចព្រមព្រៀង ដែលដាក់បញ្ចូលក្នុងមាត្រា ១៥ (១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖ "គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ *ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងអំឡុងពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើស ត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ*"។ (គូសបញ្ជាក់បន្ថែម)

[៥៩] សូមមើល រឿងក្ដី *Baskaya & Okçuoğlu* តទល់នឹង *Turkey*, Eur. Ct. H. R. App. Nos. 23536/94 & 24408/94 ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៣៦។ *សូមមើលផងដែរ* Shahram Dana, *Beyond Retroactivity to Realizing Justice: A Theory on the Principle Of Legality in International Criminal Law Sentencing*, 99(4) JOURNAL OF CRIMINAL LAW & CRIMINOLOGY, 857, 868 (2009): "មាត្រា៧ [នៃ ECHR] មានដាក់បញ្ចូលគោលការណ៍ដែលថាមានតែច្បាប់ប៉ុណ្ណោះដែលអាចកំណត់បទឧក្រិដ្ឋ និងចែងពីទោសបញ្ញត្តិ (*nullum crimen, nulla poena sine lege*) ព្រមទាំងដាក់បញ្ចូលគោលការណ៍ដែលថាច្បាប់ព្រហ្មទណ្ឌមិនត្រូវបកស្រាយឲ្យទូលំទូលាយដែលបង្កអន្តរាយដល់ជនជាប់ចោទឡើយ គួយ៉ាងការបកស្រាយដែលមានលក្ខណៈពន្យល់ប្រៀបធៀប (analogy) ឡើយ។ តាមរយៈគោលការណ៍ទាំងនេះ មាត្រានេះក៏ចែងថាបទល្មើស និងទោសបញ្ញត្តិ ត្រូវចែងឲ្យបានច្បាស់នៅក្នុងច្បាប់"។

## ក. អង្គជំនុំជម្រះសាលាដំបូង មានការភាន់ច្រឡំលើអង្គច្បាប់ដោយរំលោភសិទ្ធិដាច់ខាតរបស់លោកអៀង សារី ក្នុងការចូលរួម និងជួយក្នុងការការពារក្តីរបស់គាត់

៣៦ អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីឯកសារសំអាងផ្លូវច្បាប់ឡើយក្នុងការបង្គាប់ឱ្យលោកអៀង សារី បន្តនៅក្នុងសាលសវនាការស្តាប់សេចក្តីសន្និដ្ឋានបើក ដើម្បីឱ្យសាធារណៈជន និងភាគី អាចមើលឃើញថា គាត់កំពុងស្តាប់បទចោទប្រឆាំងនឹងគាត់[៦០]។ សេចក្តីបង្គាប់នេះមិនមានមូលដ្ឋានសំអាងឡើយ។ ដូចត្រូវបានធានានៅក្នុងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក កិច្ចព្រមព្រៀង និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ លោកអៀង សារី មានសិទ្ធិជាមូលដ្ឋានចូលរួមដោយមានប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយ ឬទាំងអស់ប្រឆាំងនឹងគាត់។ លោកអៀង សារី ត្រូវបានរារាំងមិនឱ្យចូលរួមដោយមានប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធី ដោយសារគាត់ត្រូវបានបង្ខំឱ្យនៅក្នុងសាលសវនាការ នៅពេលដែលការឈឺចាប់ផ្នែករាងកាយ និងអាការៈមិនស្រួលរបស់គាត់ ប៉ះពាល់ដល់បញ្ហាស្មារតីរបស់គាត់។ អង្គជំនុំជម្រះសាលាដំបូង បានរំលោភសិទ្ធិរបស់លោកអៀង សារី ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី និងសិទ្ធក្នុងការជួយ ដល់ការការពារក្តីរបស់ខ្លួនដោយខ្លួនឯង ជាសិទ្ធិមួយដែលត្រូវបានធានាយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ និងក្របខណ្ឌច្បាប់នៃអ.វ.ត.ក។

៣៧ សិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ក្នុងនោះមានការធានានូវសិទ្ធិជាអប្បរមាមួយចំនួន៖ **ក.** មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន[៦១] **ខ.** ទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង[៦២] និង **គ.** ត្រូវជំនុំជម្រះដោយមានវត្តមាន

---

[៦០] ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦ និងប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៨

[៦១] មាត្រា ៣៥ (ថ្មី)នៃច្បាប់ស្តីពីបង្កើតអ.វ.ត.ក មាត្រា ១៣ (១)នៃកិច្ចព្រមព្រៀង មាត្រា ១៤ (៣) (ខ)នៃ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[៦២] មាត្រា ៣៥ (ថ្មី)នៃច្បាប់ស្តីពីបង្កើតអ.វ.ត.ក មាត្រា ១៤ (៣) (ខ)នៃ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

របស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង[៦៣]។ ដើម្បីឲ្យលោក អៀង សារី អនុវត្តសិទ្ធិចូលរួមរបស់គាត់ដោយមានប្រសិទ្ធិភាព គាត់ចាំបាច់ត្រូវ "មានសម្បទារាងកាយ និងបញ្ញាស្មារតីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងគាត់[៦៤]"។ ក្នុងរឿងក្តី *Standford v. United Kingdom* ទាក់ទងនឹងជនជាប់ចោទមួយរូបដែលមិនអាចស្តាប់សក្ខីកម្មរបស់ជនរងគ្រោះមួយរូបបាន តុលាការ សិទ្ធិមនុស្សអឺរ៉ុប[៦៥] បានសម្រេចថា សិទ្ធិរបស់ជនចាប់ចោទចូលរួមដោយប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធី រួមមាន "សិទ្ធិមានវត្តមានក្នុងសវនាការ [និង] សិទ្ធិស្តាប់ និងតាមដានកិច្ចដំណើរការនីតិវិធី[៦៦]"។ អង្គជំនុំជម្រះតុលាការកំពូលគួរអនុវត្តតាមយុត្តិសាស្ត្រនេះនៅពេលពិភាក្សាសម្រេចទៅលើបណ្តឹងសាទុក្ខនេះ។

---

[៦៣] មាត្រា ៣៥ (ថ្មី)នៃច្បាប់ស្តីពីបង្កើតអ.វ.ត.ក មាត្រា ១៤ (៣) (ឃ)នៃ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[៦៤] ក្នុងរឿងក្តី *Mielke តទល់នឹងប្រទេសអាល្លឺម៉ង់* គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប ៣០០៤៧/៩៦ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ២៧-២៨។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសម្បទារបស់អៀង ធីរិទ្ធក្នុងការចូលរួមសវនាការ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E138 កថាខណ្ឌ ២៧។ ក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Strugar* IT-01-42-T សេចក្តីសម្រេចលើ បណ្តឹងរបស់មេធាវីការពារក្តីឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធី (សេចក្តីសម្រេច *Strugar*) ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៣០។

[៦៥] យុត្តិសាស្ត្រនៃគណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប ជាប្រភពមួយនៃសិទ្ធិអំណាចដែលត្រូវបានទទួលស្គាល់ និងអនុវត្តនៅអ.វ.ត.ក។ *សូមមើល ឧទាហរណ៍* ចម្លើយតបរួមរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងបណ្តឹងជិតចិត្ត ដែលត្រូវបាន ធ្វើក្នុងនាម អៀង សារី និងខៀវ សំផន ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN: 00399405-0039416 ដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ A190 n. 5, 7, 13។

[៦៦] ក្នុងរឿងក្តី *Standford តទល់នឹង* ចក្រភពអង់គ្លេស គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប 16757/90 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ កថាខណ្ឌ ២៦ *សូមមើលផងដែរ* រឿងក្តី *Colozza តទល់នឹង* ប្រទេសអ៊ីតាលី គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប 19024/80 ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៨៥ កថាខណ្ឌ ២៧ "ទោះជាមិនមានការលើកឡើងយ៉ាងច្បាស់ក្នុង[មាត្រា ៦(១)នៃ ECHR] កម្មវត្ថុ និងគោលបំណងនៃមាត្រានោះ បង្ហាញថាជនដែល "ត្រូវបានចោទពីបទល្មើសឧក្រិដ្ឋ មានសិទ្ធិចូលរួមក្នុងសវនាការ""។ *Mbenge តទល់នឹង Zaire* លិខិតទំនាក់ទំនង គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លេខ ១៦/១៩៧៧ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨៣ ("លិខិតទំនាក់ទំនង *Mbenge*") កថាខណ្ឌ ១៤.១៖ "យោងតាមមាត្រា ១៤ (៣)នៃ [ICCPR] ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់"។

៣៨ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី លោកអៀង សារី ចាំបាច់ត្រូវ *មានវត្តមានដោយមានបញ្ញាស្មារតីគ្រប់គ្រាន់*។ "វត្តមាន" មិនមានន័យថា "គ្រាន់តែជាវត្តមានដោយផ្ទាល់" របស់លោក អៀង សារី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះឡើយ[៦៧]។ ក្នុងរឿងក្តី *Strugar* អង្គជំនុំជម្រះសាលាដំបូង ICTY បានសម្រេចស្តីពីលក្ខខណ្ឌនៃវត្តមានក្នុងកិច្ចដំណើរការនីតិវិធី "គឺត្រូវបានមើលឃើញថាជាការធានានូវវត្តមានរបស់ជនជាប់ចោទ *ដែលមានសម្បទាគ្រប់គ្រាន់ជួយអង្គជំនុំជម្រះដោយបង្ហាញនូវការការពាររបស់ខ្លួន*[៦៨]"។ ជាការសមហេតុផល ដើម្បីជួយក្នុងការបង្ហាញការការពារក្តីរបស់គាត់ លោកអៀង សារី ចាំបាច់ ត្រូវអាចតាមដានដំណើរការនីតិវិធី និងប្រាស្រ័យទាក់ទងជាមួយសហមេធាវីការពារក្តីរបស់គាត់ បាន។ ដើម្បីប្រាស្រ័យទាក់ទងជាមួយសហមេធាវីការពារក្តីរបស់គាត់ លោកអៀង សារី ចាំបាច់ ត្រូវមាន"សម្បទាគ្រប់គ្រាន់ដើម្បីជូនយោបល់ដល់មេធាវីរបស់គាត់ដោយមានប្រសិទ្ធិភាព...[៦៩]"។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ "មិនត្រូវបានគោរពនៅពេលដែល...ជនជាប់ចោទ...មិនអាចជូនយោបល់ឲ្យ មេធាវីការពារក្តីគាត់បានសមស្របឡើយ[៧០]"។

៣៩ លោកអៀង សារី មានវត្តមានដោយផ្ទាល់ ដោយសារត្រូវបានបង្ខំឲ្យនៅក្នុងបន្ទប់សវនាការនោះក៏ដោយ ក៏ប៉ុន្តែស្ថានភាពសុខភាពរបស់លោកអៀង សារី រារាំងមិនឲ្យគាត់មានបញ្ញាស្មារតីគ្រប់ពេលក្នុងអំឡុងកិច្ចដំណើរការនីតិវិធីឡើយ។ លោកអៀង សារី មិនអាចចូលរួមក្នុងកិច្ចដំណើរ

---

[៦៧] សេចក្តីសម្រេចក្នុងរឿងក្តី *Strugar* កថាខណ្ឌ ៣២

[៦៨] ដូចដើងទំព័រខាងលើ (គូសបញ្ជាក់បន្ថែម)

[៦៩] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៣២ រឿងក្តីរដ្ឋអាជ្ញា *តទល់នឹង Kovačević*, IT-01-42/2-I ឯកសារសាធារណៈអំពីសេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទក្នុងការចូលរួមធ្វើសេចក្តីសន្និដ្ឋាន និងចូលរួមក្នុងសវនាការ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ២៣។

[៧០] ក្នុងលិខិតទំនាក់ទំនងក្នុងរឿងក្តី *Wolf v. Panama* លេខ 289/1988 ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្ស មាត្រាទី៥ កថាខណ្ឌ ៤ នៃពិធីសាតាមចិត្តជ្រើសរើសជាប់នឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា៥ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩២ CCPR/C/44/D/289/1988 កថាខណ្ឌ ៦.៦។

ការនីតិវិធីដោយមានប្រសិទ្ធិភាព ឬជួយក្នុងការការពារក្ដីរបស់គាត់ដោយខ្លួនឯងឡើយ នៅពេលត្រូវបានបង្ខំឲ្យនៅក្នុងបន្ទប់សវនាការ។ អ្វីដែលមិនល្អជាងនេះទៀតនោះ ការបង្ខំឲ្យគាត់បន្តស្ថិតនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះប្រថុយប្រថានធ្វើឲ្យបញ្ហាសុខភាពរបស់គាត់ដែលមានការកត់ត្រាច្បាស់លាស់ កាន់តែមានសភាពធ្ងន់ធ្ងរ ធ្វើឲ្យគ្រោះថ្នាក់ដល់សុខមាលភាពរាងកាយទាំងស្រុង និងប៉ះពាល់ដល់អាយុជីវិតរបស់គាត់ផងដែរ[៧១]។

៤០ សហមេធាវីបានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងហើយថា "(ទោះជាបានដឹងហើយថា) លោក អៀង សារី មានបញ្ហាឈឺចង្កេះឆ្អឹងខ្នងមិនអាចទ្រាំទ្រអង្គុយនៅទីនេះបានគ្រប់ពេល[៧២] អញ្ចឹង "គាត់មិនអាចស្ដាប់ គាត់ឈឺក្បាល គាត់...មានបំណងចូលរួម ប៉ុន្តែមិនអាចចូលរួមបាន។ ប្រសិនណាគាត់មិនអាចស្ដាប់បានអំពីកិច្ចដំណើរការនីតិវិធី គាត់សុំស្ដាប់នៅជាន់ខាងក្រោម[៧៣]។ ការថ្លែងនេះផ្ទុះបញ្ចាំងពីលទ្ធផលនៃរោគវិនិច្ឆ័យរបស់លោកសាស្ត្រាចារ្យ John Campbell អ្នកជំនាញព្យាបាលរោគមនុស្សចាស់ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើរោគវិនិច្ឆ័យលោក អៀងសារី ជាមួយនឹងលក្ខខណ្ឌវេជ្ជសាស្ត្រមួយចំនួន[៧៤]។ លោកសាស្ត្រាចារ្យ John Campbell ផ្ដល់អនុសាសន៍ឲ្យពិនិត្យមើលអាការៈឈឺចាប់រាងកាយ ឬភាពមិនស្រួល ដោយអនុញ្ញាតឲ្យគាត់នៅក្នុងបន្ទប់ឃុំឃាំងដែលមានឧបករណ៍ និងបរិក្ខារពិសេស។ ការអនុវត្តបែបនេះអាចឲ្យគាត់ចូលរួមបានពេញលេញក្នុងកិច្ចដំណើរការនីតិវិធី[៧៥]។ អ.វ.ត.ក (ដោយមានជំនួយពីម្ចាស់ជំនួយអន្តរជាតិ) បានបំពាក់ឧបករណ៍នៅក្នុងបន្ទប់ឃុំឃាំង ជាពិសេសដើម្បីអនុវត្តអនុសាសន៍របស់លោកសាស្ត្រាចារ្យ John Campbell និងជួយសម្រួលដល់ជនជាប់ចោទដែល

---

[៧១] សហមេធាវីការពារក្ដី ជម្រុញឲ្យអង្គជំនុំជម្រះតុលាការកំពូលឲ្យអ្នកជំនាញចូលរួមក្នុងការពិនិត្យឡើងវិញនូវប្រវត្តិសុខភាពរបស់លោកអៀង សារី

[៧២] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៣៦

[៧៣] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ១-៣

[៧៤] របាយការណ៍របស់ Campbell កថាខណ្ឌ ១២ ១៧ និង២២

[៧៥] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣០

មានវ័យជរា ដើម្បីឲ្យជនជាប់ចោទអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយ។ អ.វ.ត.ក បានរៀបចំកៅអីទម្រេតខ្លួន[៧៦] ឧបករណ៍សោតទស្សន៍ និងភ្ជាប់ខ្សែទូរស័ព្ទក្នុងបន្ទប់ឃុំឃាំងដើម្បីទាក់ទងគ្នាទៅវិញទៅមករវាង លោកអៀង សារី និងសាលសវនាការ[៧៧]។ ឧបករណ៍បរិក្ខារទាំងនេះត្រូវបានរៀបចំ និងដំឡើងដោយយកចិត្តទុកដាក់ ដោយពិចារណាពីសិទ្ធិ និងតម្រូវការរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២។

៤១ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធដោយមានៈមិនអនុវត្តតាមលទ្ធផល និងអនុសាសន៍របស់អ្នកជំនាញដែលខ្លួនបានចាត់តាំងដោយផ្ទាល់ឡើយ ដែលផ្តល់យោបល់ថា អង្គជំនុំជម្រះសាលាដំបូង គប្បីអនុញ្ញាតឲ្យលោក អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំដែលមានរៀបចំឧបករណ៍ជាពិសេស។ អង្គជំនុំជម្រះសាលាដំបូង បានបង្ខំឲ្យលោក អៀង សារី មានវត្តមានដោយផ្ទាល់ក្នុងសាលសវនាការ ទាំងចេតនា និងដោយដឹងជាមុនយ៉ាងច្បាស់ថា គាត់មិនមានបញ្ហាស្មារតីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅពេលនោះទេ។ វាជាការរារាំងមិនឲ្យលោក អៀង សារី អនុវត្តសិទ្ធិជាមូលដ្ឋានរបស់គាត់ដើម្បីចូលរួម និងជួយក្នុងការការពារក្តីរបស់គាត់ ហើយជាការរំលោភលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុង[៧៨]។ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

---

[៧៦] សារអេឡិចត្រូនិកពី Matteo Crippa ទីប្រឹក្សាផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូន Tanya Pettay អ្នកពិគ្រោះយោបល់ផ្នែកច្បាប់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី យោងៈ ផ្ញើបន្តៈ ការអនុវត្តរបាយការណ៍វេជ្ជសាស្ត្រធ្វើឡើងដោយអ្នកជំនាញ "កៅអីទម្រេតខ្លួន" សម្រាប់លោក អៀង សារី ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១។

[៧៧] ប្រតិចារឹកនៃសវនាការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/4.1 ទំព័រ ៦៣ អនុស្សរណៈអន្តរការិយាល័យពី John Downard អ្នកគ្រប់គ្រងផ្នែកសោតទស្សន៍ នៃផ្នែកគ្រប់គ្រងតុលាការ ផ្ញើជូន Rupert Abbott ប្រធានស្តីទីអង្គភាពគាំពារការពារក្តី យោងៈ បច្ចុប្បន្នភាពស្តីពីឧបករណ៍សម្រាប់ការចូលរួមតាមប្រព័ន្ធសោតទស្សន៍ (Videoconference) ថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០១១ ។ នៅក្រោយឆាកៈ បន្ទប់ឃុំឃាំង សូមមើល http://www.eccc.gov.kh/en/articles/behind-scenes-holding-cells

[៧៨] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងមាត្រា ១៣ (១) នៃកិច្ចព្រមព្រៀង

តាមរយៈការរារាំងដោយបានដឹងច្បាស់ជាមុន និងដោយចេតនានូវការអនុវត្តសិទ្ធជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី។

**ខ. អង្គជំនុំជម្រះសាលាដំបូង បានភាន់ច្រឡំលើអង្គច្បាប់ និងអង្គហេតុ បានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន និងជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយមិនបានយកចិត្តទុកដាក់ចំពោះការបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការ**

**១. អង្គជំនុំជម្រះសាលាដំបូង បានភាន់ច្រឡំលើអង្គច្បាប់ដោយមិនអើពើចំពោះការបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការរបស់លោក អៀង សារី**

៤២ អង្គជំនុំជម្រះសាលាដំបូង បដិសេធមិនទទួលការបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការរបស់លោក អៀង សារី ទោះជាគាត់មានមេធាវីរបស់គាត់ធ្វើតំណាងក៏ដោយ[៧៩]។ លោក អៀង សារី មិនបានស្នើបោះបង់សិទ្ធិចូលរួមក្នុងសវនាការឡើយ (ក៏ប៉ុន្តែក្រុមមេធាវីការពារក្តីស្នើឡើងថា ជនជាប់ចោទអាចបោះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការ ក្នុងករណីគាត់មានមេធាវីធ្វើតំណាង[៨០])។ គាត់គ្រាន់តែមានបំណងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ ដែលមានរៀបចំឧបករណ៍ជាពិសេស។

៤៣ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និង ICCPR (ដែលត្រូវបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា) ទទួលស្គាល់សិទ្ធិរបស់លោក អៀង សារី ក្នុងការជំនុំជម្រះដោយមានវត្តមានរបស់គាត់[៨១]។ វិធាន ៨១ វិធាននីតិវិធីអន្តរជាតិ យុត្តិសាស្ត្រ និងការអនុវត្ត ចែងថាលោក អៀង សារី អាចបោះបង់សិទ្ធមានវត្តមានក្នុងពេលសវនាការដោយស្ម័គ្រចិត្ត បើសិនជាគាត់មានមេធាវីធ្វើតំណាង។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ (មុនពេល*ផ្លាស់ប្តូរមតិ*

---

[៧៩] ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៨

[៨០] *សូមមើល* សេចក្តីសង្កេត កថាខណ្ឌ ១៥

[៨១] មាត្រា ៣៥ ថ្មី (ឃ) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា ១៤ (៣) (ឃ) នៃ ICCPR

*យោបល់ទាំងស្រុង* របស់ខ្លួន) ថា លោក អៀង សារី "មានសិទ្ធិបោះបង់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមនៅក្នុងសវនាការ... មិនអាច បង្ខំឲ្យស្ថិតនៅក្នុងសាលសវនាការទេ[៨២]"។ អង្គជំនុំជម្រះក៏បានថ្លែងថា "នៅពេលជន ជាប់ចោទណាម្នាក់លះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ ជនជាប់ចោទរូបនោះ អាចត្រឡប់ ទៅបន្ទប់រង់ចាំស្ថិតនៅក្រោមបន្ទប់សវនការដែលមានឧបករណ៍សោតទស្សន៍ សម្រួលដល់ការ ទំនាក់ទំនងជាមួយក្រុមមេធាវីការពារក្តីរបស់ខ្លួន និងចូលរួមដំណើរការនីតិវិធីបាន[៨៣]"។ លោក អៀង សារី បានអនុវត្តទាំងស្រុងតាមការលើកឡើងនេះ។ គាត់បានអនុវត្តការបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនការ ដែលមិនចាំបាច់បង្ខំខ្លួនឯងឲ្យមានវត្តមានក្នុងបន្ទប់សវនាការឡើយ។ ការភាន់ច្រឡំលើអង្គច្បាប់ដោយអង្គជំនុំជម្រះ សាលាដំបូង បានរំលោភសិទ្ធិតាមនីតិវិធីរបស់លោកអៀង សារី ក្នុងការបោះបង់សិទ្ធិមានវត្តមាន ក្នុងសាលសវនាការ ហើយការអនុវត្តដូច្នេះជាការរំលោភសិទ្ធិដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និងសិទ្ធដាច់ខាតក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងជួយក្នុងការការពារក្តីគាត់។ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមរយៈការរារាំងដោយបានដឹងច្បាស់ជាមុន និងដោយចេតនានូវការអនុវត្តសិទ្ធជាមូលដ្ឋាននៃការជំនុំជម្រះ ក្តីដោយយុត្តិធម៌របស់លោក អៀង សារី។

### ក. អនុលោមតាមការអនុវត្តជាអន្តរជាតិ លោកអៀង សារី អាចបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការ

៨៤ វិធាននីតិវិធីអន្តរជាតិ យុត្តិសាស្ត្រ និងការអនុវត្ត កំណត់ថា លោក អៀង សារី មិនត្រូវបានតម្រូវឲ្យបង្ហាញខ្លួនក្នុងពេលសវនាការ ប្រសិនបើគាត់បោះបង់សិទ្ធិចូលរួមក្នុងសវនាការដោយចេតនាស្ម័គ្រចិត្ត និងពិតប្រាកដ ហើយគាត់មានមេធាវីការពារក្តីធ្វើជាតំណាង។ ទោះបីជាមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "ជនជាប់ចោទត្រូវបង្ហាញខ្លួននៅ

---

[៨២] ប្រតិចារឹក ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១១ E1/12.1 ទំព័រ ១៣៦-១៣៧

[៨៣] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ទំព័រ ២។ *សូមមើលផងដែរ* ប្រតិចារឹកកិច្ចប្រជុំរៀបចំសវនាការ ទំព័រទី ២១-២២

ពេលសវនាការរបស់តុលាការដោយផ្ទាល់[៨៤]" ក៏មាត្រា ៣៣៣ ចែងថា តុលាការអាចបន្តកិច្ច ដំណើរការនីតិវិធី ទោះបីជនជាប់ចោទអវត្តមានក៏ដោយ។ បើទោះជាក្នុងច្បាប់ជាតិមួយចំនួន ជនជាប់ចោទអាចត្រូវមានកាតព្វកិច្ចបង្ហាញខ្លួនក្នុងពេលសវនាការ ប៉ុន្តែនៅ អ.វ.ត.ក វាមិន កំណត់បែបនេះទេ។ បើសិនជាមិនមានភាពច្បាស់លាស់ក្នុងការបកស្រាយ ឬក្នុងការអនុវត្តនីតិវិធី ដែលមានស្រាប់ អង្គជំនុំជម្រះសាលាដំបូងអាចស្នើសុំគោលការណ៍ណែនាំពីវិធាននីតិវិធីនានាក្នុង កម្រិតអន្តរជាតិ[៨៥]។ បើសិនជានៅតែមានភាពមិនច្បាស់លាស់បន្ទាប់ពីអនុវត្តវិធាននៃការបក ស្រាយច្បាប់ Civil Law នោះត្រូវអនុវត្តការបកស្រាយណាមួយដែលផ្តល់ប្រយោជន៍ច្រើនបំផុត ដល់ជនជាប់ចោទ[៨៦]។

---

[៨៤] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង មាត្រា ៣១៩ និង ៣២០ ។ រឿងក្តី *Lala តទល់នឹងប្រទេសហូឡង់ គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប* លេខ14861/89 កថាខណ្ឌ ១៤ (យោង ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសហូឡង់ ផ្នែក ២៧២)។ *សូមមើល* រឿងក្តី *R តទល់នឹង O'Boyle* (1991) Cr. App. R. 202, 208. *ប្រៀបធៀប* U.S. Fed. R. Crim. ទំព័រ ៤៣ ដែល អនុញ្ញាតឱ្យបោះបង់សិទ្ធិរបស់ជនចាប់ចោទក្នុងការបង្ហាញខ្លួន។ បន្ទាប់ពីការបង្ហាញខ្លួនលើកដំបូង ជនជាប់ចោទ អាចអវត្តមាន ដោយស្ម័គ្រចិត្តបន្ទាប់ពីសវនាការចាប់ផ្តើម។

[៨៥] *សូមមើល* មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ *សូមមើល ឧទាហរណ៍* សាលក្រម *សំណុំរឿងកាំង ហ្កេកអ៊ាវ ហៅ ឌុច* 001/18-07 2007/អ.វ.ត.ក/អ.ជ.ស.ដ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១០ E188 កថាខណ្ឌ ៣៥។ សេចក្តី សម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារលេខ E51/3, E82, E88 និង E92) ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E116 កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់នួន ជា ពាក់ព័ន្ធ នឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ E51/4 សេចក្តីសម្រេច លើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ E5/3 កថាខណ្ឌ ៣, ៦, ៧។

[៨៦] *សូមមើល* រដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣៨៖ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"; សេចក្តីសម្រេចលើ បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E50/3/1/4, កថាខណ្ឌ ៣១៖ "ចំពោះគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះ ស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះត្រូវបានកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការបក ស្រាយ។ ហេតុដូច្នេះ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវ ចំពោះភាព មន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិដែលនៅតែមានក្រោយការអនុវត្តនូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយពិចារណាលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗ

៤៥ ក្នុងរឿងក្តី *Delalié et al.* អង្គជំនុំជម្រះសាលាដំបូង ICTY ទទួលស្គាល់ថា សិទ្ធិមានវត្តមានក្នុងពេលសវនាការ ជាសិទ្ធិរបស់ជនជាប់ចោទ "អាស្រ័យហេតុនេះ មិនមានផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី អាចប្រព្រឹត្តទៅបានដោយគ្មានវត្តមានរបស់ជនជាប់ចោទឡើយ បើសិនជាគាត់មិនបោះបង់សិទ្ធិរបស់គាត់ និងអនុញ្ញាតឱ្យ [មេធាវីការពារក្តី] របស់គាត់ធ្វើជាតំណាង[៨៧]"។ ស្រដៀងគ្នានេះដែរ ក្នុងរឿងក្តី *Nahimana* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) សម្រេចថា "ទោះជាយ៉ាងណា សិទ្ធិរបស់ជនជាប់ចោទទទួលបានការជំនុំជម្រះក្តី ដោយមានវត្តមានរបស់ខ្លួន មានចែងយ៉ាងច្បាស់ក្នុងច្បាប់អន្តរជាតិដែល [មិន]...រារាំងអ្នកទទួលបានសិទ្ធិនោះក្នុងការអនុវត្តសិទ្ធិនោះឡើយ"[៨៨]។

៤៦ នៅ ICTR និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បើសិនជាជនជាប់ចោទបដិសេធមិនបង្ហាញខ្លួនក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ អង្គជំនុំជម្រះអាចបង្គាប់ឱ្យបន្តសវនាការដោយគ្មានវត្តមានរបស់ជនជាប់ចោទ ឲ្យតែ៖ **ក.** ជនជាប់ចោទបានបង្ហាញខ្លួនលើកដំបូង **ខ.** ជនជាប់ចោទទទួលបានដំណឹងថា អង្គជំនុំជម្រះសាលាដំបូងតម្រូវ

---

ដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"។ *សូមមើលផងដែរ* លក្ខន្តិកៈតុលាការ ICC, មាត្រា ២២៖ "១. គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ លើកលែងតែ ការប្រព្រឹត្តនោះបង្កបង្កើតនៅពេលកើតឡើងនូវបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងយុត្តាធិការតុលាការ។ ២.និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយការពន្យល់ប្រៀបធៀប (analogy) ឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះត្រូវបានបកស្រាយជាប្រយោជន៍ដល់ជនកំពុងត្រូវរងការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព។ ៣.មាត្រានេះ មិនត្រូវប៉ះពាល់ដល់ការស្តែងចរិកលក្ខណៈនៃការប្រព្រឹត្តណាមួយ ដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ឯករាជពីច្បាប់លក្ខន្តិកៈនេះឡើយ"។

[៨៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកដទៃ* IT-96-21-T ប្រតិចារឹក ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៨៩៧៣

[៨៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Nahimana *និងអ្នកដទៃ* ICTR-99-52-A សាលក្រម ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (សាលដីការឿងក្តី *Nahimana*) កថាខណ្ឌ ១០៧។ *សូមមើលផងដែរ* លិខិតទំនាក់ទំនង *Mbenge* កថាខណ្ឌ ១៤.១។

ឲ្យគាត់មានវត្តមានក្នុងពេលសវនាការ និង **គ.** ជនជាប់ចោទត្រូវបានតំណាងដោយមេធាវី[៨៩]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTR បានសម្រេចថា ការបោះបង់សិទ្ធិរបស់ជនណាម្នាក់ក្នុងការមានវត្តមានក្នុងពេលសវនាការ អាចធ្វើបានដោយតុណ្ហីភាព ឬយ៉ាងច្បាស់ ប៉ុន្តែ "ត្រូវធ្វើឡើងដោយ "គ្មានការបង្ខិតបង្ខំ និងជាក់លាក់ច្បាស់លាស់[៩០]"។ ការបោះបង់សិទ្ធិរបស់ជនជាប់ចោទម្នាក់ ត្រូវបង្ហាញថា គាត់ដឹងអំពី **ក.** ទីកន្លែង និងកាលបរិច្ឆេទនៃសវនាការ **ខ.** បទចោទប្រឆាំងរូបគាត់ **គ.** សិទ្ធិមានវត្តមានក្នុងពេលសវនាការ **ឃ.** កាតព្វកិច្ចរបស់គាត់ដែលត្រូវបង្ហាញខ្លួនក្នុងពេលជំនុំជម្រះ និង **ង.** ផលវិបាកនៃការបោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការ[៩១]។ ក្នុងករណីនេះ លោក អៀង សារី ត្រូវបានកោះហៅដោយសមស្របឲ្យបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបើក[៩២]។ លោក អៀង សារី ទទួលបានការជូនដំណឹងក្នុងអំឡុងពេលសវនាការពេលមុនៗអំពីបទចោទប្រឆាំងរូបគាត់[៩៣] និងដឹងអំពីផលវិបាកនៃការបោះបង់សិទ្ធិមិនមានវត្តមានក្នុងពេលសវនាការ។ នេះជាសិទ្ធិតាមផ្លូវច្បាប់របស់លោក អៀង សារី ក្នុងការបោះបង់សិទ្ធមានវត្តមានក្នុងពេលសវនាការ។

---

[៨៩] វិធាននីតិវិធី និងភស្តុតាងរបស់ ICTR កថាខណ្ឌ ៨២ ស្ទួន។ វិធាន ៦០ នៃ វិធាននីតិវិធី និងភស្តុតាងរបស់ SCSL។ *សូមមើលផងដែរ* សាលាក្តីពិសេសសម្រាប់លក្ខន្តិកៈប្រទេសលីបង់ មាត្រា ២២ (១) (ក)។

[៩០] សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ១០៩។ *សូមមើលជើងទំព័រខាងលើ* n. 213 *ដកស្រង់រឿងក្តី* Battisti *តទល់នឹងប្រទេសបារាំង* គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប 28769/05 ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦។

[៩១] សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ១០៩។ *សូមមើលផងដែរ* លិខិតទំនាក់ទំនង *Mbenge* កថាខណ្ឌ ១៤.១។

[៩២] ដីកាកោះហៅ - ជនជាប់ចោទ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ E131/7

[៩៣] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ C19 ។ កំណត់ហេតុសួរចម្លើយជនជាប់ចោទ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ D282 ទំព័៥ ៣-៥ សវនការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/4.1 ទំព័រ ១។

៤៧ ទោះបីជាលោក អៀង សារី បោះបង់សិទ្ធិមានវត្តមានក្នុងពេលសវនាការក៏ដោយ សិទ្ធិរបស់គាត់នៅតែត្រូវបានការពារដោយសហមេធាវីរបស់គាត់ដែលមានវត្តមានក្នុងសាលសវនាការ[៩៤]។ សិទ្ធិរបស់លោក អៀង សារី ដែលត្រូវបានការពារពីមេធាវី ជាការធានាក្នុងកម្រិតអប្បបរមាក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌[៩៥]។ សហមេធាវីការពារក្តីលោក អៀង សារី មានកាតព្វកិច្ចការពារក្តីដោយប្រឹងប្រែង និងយកចិត្តទុកដាក់ និង "ការពារក្តីដោយសកម្មដើម្បីជាប្រយោជន៍ច្រើនបំផុតដល់[កូនក្តីរបស់ខ្លួន]"[៩៦]។ វាមិនចាំបាច់លើកឡើងឡើយដែលថាមេធាវីការពារក្តីពិតជាបានផ្តល់នូវការការពារក្តីយ៉ាងស្វាហាប់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី[៩៧]។ បើសិនលោក អៀង សារី

---

[៩៤] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E5/3 កថាខណ្ឌ ២ ទាក់ទិនកាតព្វកិច្ចនៃការយកចិត្តទុកដាក់ហ្មត់ចត់។

[៩៥] មាត្រា ១៤ (៣) (ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *សូមមើលផងដែរ រឿងក្តី Van Geyseghem តទល់នឹង ប្រទេសបែលហ្ស៊ិក* គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប លេខ 26103/95 ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៤។

[៩៦] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Barayagwiza*, ICTR-97-19-T សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីដើម្បីដកខ្លួនចេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២000 កថាខណ្ឌ ២១។ *សូមមើលផង សាលដីការឿងក្តី Nahimana* កថាខណ្ឌ ១០៩ " នៅពេលដែលជនជាប់ចោទ ...ធ្វើការសម្រេចចិត្តដោយស្ម័គ្រចិត្តមិនមានវត្តមាននៅពេលសវនាការ វាជាប្រយោជន៍យុត្តិធម៌ក្នុងការតែងតាំងមេធាវីរបស់គាត់ ជាពិសេស ធានាឲ្យបានការអនុវត្តដោយប្រសិទ្ធិភាពនូវសិទ្ធិដទៃទៀត ដែលមានចែងក្នុងមាត្រា ២០ នៃលក្ខន្តិកៈ [សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌]" ។ ក្នុងរឿងក្តី *Tadić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ក៏បានថ្លែងថាគោលបំណងនៅក្នុងលក្ខន្តិកៈ ICTY ទាក់ទងនឹងសិទ្ធិមួយចំនួនរបស់ជនជាប់ចោទនោះគឺថា "ជនជាប់ចោទ គប្បីប្រឹងប្រែងអនុវត្តឲ្យបានសមស្របក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន"។ ភស្តុតាងឧក្រិដ្ឋកម្មអន្តរជាតិ (INTERNATIONAL CRIMINAL EVIDENCE 306) ដោយ JUDGE RICHARD MAY & MARIEKE WIERDA, INTERNATIONAL CRIMINAL EVIDENCE (បោះពុម្ពផ្សាយដោយ Transnational Publishers Inc. ឆ្នាំ ២00២) *ពិភាក្សាអំពីរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-A សេចក្តីសម្រេចលើបណ្តឹងម្ចាស់បណ្តឹងឧទ្ធរណ៍ឲ្យពន្យារការដាក់កម្រិតពេលវេលា និងការទទួលយកភស្តុតាងបន្ថែម ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៨។

[៩៧] ចន្លោះពីថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២00៧ រហូតដល់ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់សារណាក្នុងនាមលោក អៀង សារី ជាអប្បបរមាចំនួន ៣៥៥។ មេធាវីការពារក្តីក៏បានបង្កើតគេហទំព័រមួយ (https://sites.google.com/site/iengsarydefence/) ដើម្បីធានាពីតម្លាភាពជាអតិបរមា។ *សូមមើលផងដែរ ឧទាហរណ៍* អនុស្សារណៈពីអ្នកស្រី Nisha Valabhji មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី ("DSS") ផ្ញើជូនលោក អាង ឧត្តម និង លោក Michael G. Karnavas សហមេធាវី

មិននមានវត្តមានក្នុងសាលសវនាការ ហើយចូលរួមក្នុងកច្ចិដំណើរការនីតិវិធីពីបន្ទប់រង់ចាំ សហមេធាវីរបស់គាត់ *ត្រូវ* និង *នឹង* ការពារសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

## ខ. វិធាន ៨១ ទទួលស្គាល់ការបោះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការរបស់លោក អៀង សារី

៤៨ ស្របតាមវិធាននីតិវិធីអន្តរជាតិ យុត្តិសាស្ត្រ និងការអនុវត្ត វិធាន៨១ ទទួលស្គាល់យ៉ាងច្បាស់នូវការបោះបង់សិទ្ធិមានវត្តមានក្នុងសាលសវនាការរបស់លោក អៀង សារី ។ ក្នុងបណ្តឹងសាទុក្ខនេះ បទប្បញ្ញត្តិដែលពាក់ព័ន្ធនៃវិធាន ៨១ មានចែងក្នុងវិធាន ៨១ (៤) និងវិធាន ៨១ (៥)[៥៨]។ វិធាន

---

ការពារក្តីលោក អៀង សារី, កម្មវត្ថុ៖ អង្គជំនុំជម្រះសាលាដំបូងយោងទៅដល់សំណើរបស់លោក អៀង សារី (E53/2 និង E65) និងញត្តិរបស់លោក អៀង សារី (E70, E69, E71) ផ្ញើជូន DSS សុំឱ្យពិនិត្យឡើងវិញទៅតាមអំណាចរបស់អង្គភាពនេះ ដើម្បីបដិសេធនូវការទូទាត់ការចំណាយលើការងារមួយផ្នែកដែលបានស្នើសុំ, ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១ ដែលក្នុងនោះ DSS បានអនុម័តទូទាត់ការចំណាយទាំងស្រុង ទាក់ទិននឹងការដាក់សារណាចំនួនប្រាំ ដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យអង្គភាពនេះពិនិត្យឡើងវិញទៅតាមអំណាចរបស់ DSS ក្នុងការបដិសេធនូវការទូទាត់ការចំណាយមួយផ្នែកដែល "មិនចាំបាច់ និងមិនសមហេតុផល"។ *សូមមើលផងដែរ* Andrew Cayley, *ក្រុមមេធាវីការពារក្តី អៀង សារី មិនចាំបាច់សូមអភ័យទោសចំពោះការធ្វើការងាររបស់ខ្លួនទេ Ieng Sary Defence Team Need Not Apologise For Doing Its Job*, ព្រឹត្តិប័ត្រព័ត៌មាន ខឹកម្ពុជាដេលី, ចេញផ្សាយថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១១, ទំព័រ ៣៤៖ "តុលាការនេះមានលក្ខណៈពិសេស ហើយភាគីនានាជាអ្នកលើកឡើងនូវបញ្ហាបច្ចេកទេសច្បាប់ដែលពាក់ព័ន្ធនឹងតុលាការនេះ បន្ទាប់មកចៅក្រមជាអ្នកសម្រេច។ លោក អាង ឧត្តម និងលោក Michael Karnavas គ្រាន់តែបំពេញការងាររបស់ខ្លួនតែប៉ុណ្ណោះ នោះជាអ្វីដែលគេរំពឹង"។

[៥៨] វិធាន ៨១ (៣) មិនអាចបកស្រាយបានថាលោក អៀង សារី ត្រូវមានវត្តមានក្នុងបន្ទប់សវនាការក្នុងអំឡុងពេលសវនាការឡើយ។ នៅពេលពិនិត្យមើលបរិបទទាំងស្រុងនៃវិធាន ៨១ វិធាន ៨១ (៣) អនុវត្តបានចំពោះកិច្ចដំណើរការនីតិវិធី*មុនពេល និងក្នុងអំឡុងពេល*បង្ហាញខ្លួនលើកដំបូង។ អនុវិធាននៃវិធាន ៨១ លើកឡើងតាមលំដាប់លំដោយនៃដំណាក់កាលផ្សេងៗនៃកិច្ចដំណើរការនីតិវិធីនៅចំពោះអង្គជំនុំជម្រះ។ វិធាន ៨១ (១) ចែងអំពីគោលការណ៍ទូទៅដែលលោក អៀង សារី ត្រូវជំនុំជម្រះក្តីដោយមានវត្តមានរបស់គាត់។ វិធាន ៨១ (២) លើកកិច្ចដំណើរការនីតិវិធ*មុនពេល*ការបង្ហាញខ្លួនលើកដំបូងរបស់លោក អៀង សារី ដូចបានចែងថា "ជនជាប់ចោទត្រូវនាំមកកាន់មន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ រហូតដល់ពេលជនជាប់ចោទរូបនេះត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ វិធាន ៨១ (៦) លើកឡើងអំពីការការសាកសួរលោកអៀង សារី ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីអង្គសេចក្តី*បន្ទាប់ពី*ការបង្ហាញខ្លួនលើកដំបូង។ វិធាន ៨១ (៧) លើកឡើងអំពីអវត្តមាន

៨១ (៤) ពាក់ព័ន្ធនឹងជនជាប់ចោទដែលត្រូវបានកោះហៅឲ្យចូលរួមក្នុងសវនាការបន្ទាប់ពីការបង្ហាញខ្លួនលើកដំបូងរបស់ខ្លួន ដោយចែងអំពីការបោះបង់សិទ្ធិបង្ហាញខ្លួនរបស់លោកអៀង សារី ក្នុងពេលសវនាការ បើសិនជាគាត់ "បដិសេធ ឬខកខានមិនបានចូលរួម ឬត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធី[៩៩]"។ វិធាន ៨១ (៥) អនុញ្ញាតឲ្យលោក អៀង សារី បោះបង់សិទ្ធិបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ នៅពេលគាត់មិនអាចចូលរួមដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ដោយសារបញ្ហាសុខភាព ឬបញ្ហាធ្ងន់ធ្ងរដទៃទៀត ប៉ុន្តែរូបកាយ និងស្មារតីសមស្របអាចចូលរួមក្នុងដំណើរការនីតិវិធីបាន។ ក្នុងករណីលោក អៀង សារី មិនមានវត្តមានក្នុងសាលសវនាការ វិធាន ៨១ (៤) និង ៨១ (៥) ធានាថា "គាត់ទទួលបានការពារ ក្នុងដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន"។

៤៩ លោក អៀង សារី បានស្នើសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ និងសុំចូលរួមកិច្ចដំណើរការនីតិវិធីពីចម្ងាយ ដែលអាចអនុវត្តទៅបានដោយអនុលោមតាម វិធាន ៨១ នៃវិធានផ្ទៃក្នុង។ ដើម្បីជៀសវាងនូវការពន្យារពេលច្រើន ដោយសារស្ថានភាពសុខភាពរបស់គាត់នោះ លោក អៀង សារី បានស្នើសុំចូលរួមកិច្ចដំណើរការនីតិវិធីពីចម្ងាយ តាមរយៈមធ្យោបាយសោតទស្សន៍[១០០]។ សំណើសុំនេះនៅតែត្រូវបានធ្វើឡើង បើទោះជាក្រុមមេធាវីការពារក្តីរបស់គាត់

---

របស់ជនជាប់ចោទពីកិច្ចដំណើរការនីតិវិធី។ *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30, n.267 ទាញសំអាងមាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ដែលបញ្ជាក់បង្ហាញអំពីវិធាននៃការបកស្រាយបទប្បញ្ញត្តិច្បាប់។

[៩៩] វិធាន ៨១ (៤) *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានរបស់លោកចៅក្រម Lavergne ក្នុងអំឡុងពេលសវនាការបឋម "វិធាននេះទាក់ទងនឹងករណីដែលថាជនជាប់ចោទជំទាស់មិនព្រមបង្ហាញខ្លួន។ ហើយក្នុងករណីនេះ គឺថាគេអាចបញ្ជូនគាត់មកអង្គជំនុំជម្រះ ហើយនឹងគេបង្ហាញពីសិទ្ធិរបស់គាត់ ដែលថាទទួលបានពីមេធាវីមួយការពារ។ ហើយគាត់ក៏អាចមិនព្រមទទួលមកបង្ហាញខ្លួនផងដែរ" ។ ប្រតិចារឹកសវនាការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ E1/4.1 ទំព័រ ៧៥។ *សូមមើលផងដែរ* ទំព័រ ៧៦ លោកចៅក្រម Lavergne បញ្ជាក់ថាគាត់យោងលើវិធាន ៨១ (៤)។

[១០០] *សូមមើល* វិធាន ៨១ (៥) នៃវិធានផ្ទៃក្នុង។

បានស្នើឡើងថា លោក អៀង សារី មិនអាចត្រូវបាន*ចាប់បង្ខំ* ឱ្យចូលរួមកិច្ចដំណើរការនីតិវិធីឡើយ សូម្បីតែតាមរយៈមធ្យោបាយសោតទស្សន៍ក៏ដោយ[១០១]។

## ២. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុ ហើយបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយលើកឡើងនូវសំអាងហេតុ ដើម្បីចាប់បង្ខំ លោក អៀង សារី ឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ

៥០ បើទោះជាក្រុមមេធាវីការពារក្តីលើកឡើងថា លោក អៀង សារី មានសិទ្ធិអវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធី ដោយមានមេធាវីតំណាងនៅក្នុងបន្ទប់សវនាការ ប្រសិនបើគាត់សម្រេចយ៉ាងដូច្នេះដោយស្ម័គចិត្ត ត្រឹមត្រូវ និងច្បាស់លាស់នោះក៏ដោយ នៅក្នុងករណីមួយនេះ លោក អៀង សារី គ្រាន់តែស្នើសុំអវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ ដោយមូលហេតុស្ថានភាពសុខភាពរបស់គាត់តែប៉ុណ្ណោះ ហើយអវត្តមានរបស់គាត់ក្នុងករណីមួយនេះ មិនមែនជាអវត្តមានសម្រាប់កិច្ចដំណើរការនីតិវិធីទាំងមូលនោះទេ។ លោក អៀង សារី មានបំណងចូលរួមកិច្ចដំណើរការនីតិវិធីនាពេលនោះ និងជួយដល់ការការពារក្តីរបស់គាត់ពីបន្ទប់រង់ចាំ ដែលត្រូវបានរៀបចំយ៉ាងពិសេស និងមានបំពាក់ឧបករណ៍ ដើម្បីអាចឱ្យគាត់អាចតាមដានកិច្ចដំណើរការបាន ខណៈពេលដែលគាត់អាចសម្រួលដល់ស្ថានភាពសុខភាពរបស់គាត់បានផងដែរ។

៥១ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតឱ្យមានលក្ខណៈវិនិច្ឆ័យសិប្បនិម្មិត (ដោយមិនមានឯកសារសំអាងផ្លូវច្បាប់ណាមួយ) ដើម្បីចាប់បង្ខំឱ្យជនជាប់ចោទត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ បើទោះជាជនជាប់ចោទបានលះបង់ ដោយស្ម័គចិត្ត ត្រឹមត្រូវ និងច្បាស់លាស់នូវសិទ្ធិមានវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ ដោយមូលហេតុសុខភាពហើយក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ជនជាប់ចោទអាចត្រូវបានបង្គាប់ឱ្យមានវត្តមាននៅក្នុងតុលាការ "ក្នុងករណីចាំបាច់សម្រាប់ឱ្យអង្គជំនុំជម្រះអនុវត្តតួនាទីរបស់ខ្លួន ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ" ឬ "ក្នុងករណីដែលវត្តមានរបស់ជនជាប់ចោទ ត្រូវតែមានដោយខានពុំបាន សម្រាប់ប្រសិទ្ធភាពនៃ

---

[១០១] *សូមមើល* សេចក្តីសង្កេត កថាខណ្ឌ ១៥។

ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី”[១០២]។ គួរឲ្យសរសើរដូចដែលយើងស្តាប់បាន នៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យលោកអៀង សារី ត្រូវមានវត្តមាននៅក្នុង តុលាការដើម្បីស្តាប់សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ និងដើម្បីបង្ហាញឱ្យសាធារណជន និង ភាគីនានាឃើញថា គាត់បានស្តាប់បទចោទប្រកាន់ទាំងឡាយប្រឆាំងលើរូបគាត់[១០៣]។ សំអាងហេតុទាំងនេះមិនមានចែងនៅក្នុងវិធាននានា ឬនៅក្នុងវិធានស្តីពីនីតិវិធី យុត្តិសាស្ត្រ ឬការអនុវត្តជាអន្តរជាតិហើយក៏មិនស្ថិតនៅក្នុងលក្ខខណ្ឌពិសេសពីរ ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្កើតឡើងនោះដែរ។ តាមរយៈសំអាងហេតុ ដែលគ្មានសុពលភាព និងដោយអត្តនោម័តរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសម្រេចបដិសេធចោលការលះបង់សិទ្ធិដែលមានសុពលភាពរបស់លោក អៀង សារី ចំពោះការមានវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ។

៥២ ជារឿងគួរឱ្យចម្លែកមួយ ដែលអង្គជំនុំជម្រះសាលាដំបូង ជាជាងការពារសិទ្ធិរបស់ លោក អៀង សារី ដោយចាប់បង្ខំរូបគាត់ឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការនោះ បែរជាមិនពិចារណាទៅលើសិទ្ធិដែលមានធម្មនុញ្ញភាព ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីដោយមានប្រសិទ្ធិភាព និងសិទ្ធិក្នុងការលះបង់សិទ្ធិមានវត្តមានរបស់ លោក អៀង សារី ទៅវិញ។ តាមការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។ វត្តមានរបស់ លោក អៀង សារី នៅក្នុងបន្ទប់សវនាការ មិនត្រូវការជាចាំបាច់ដោយខានពុំបាន សម្រាប់ការប្រព្រឹត្តិទៅដោយមានប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនោះឡើយ។ គោលបំណងនៃកិច្ចដំណើរការនីតិវិធីនាពេលនោះ គឺសម្រាប់ឱ្យភាគីនានាផ្តល់សេចក្តីសន្និដ្ឋានបើករបស់ខ្លួន។ វាជាការដាក់ច្បាស់សេចក្តីសន្និដ្ឋានបើក មិនមែនជាភស្តុតាង ឬជាទឡ្ហីករណ៍នោះទេ[១០៤]។ សេចក្តីសន្និដ្ឋានបើក ដោយភាគី

---

[១០២] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ ២។

[១០៣] ប្រតិចារឹត ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦។ ប្រតិចារឹត ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៨។

[១០៤] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសវនាការសម្រាប់សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ និងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង 00២ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131 ទំព័រ ៣ ដែលអង្គជំនុំ ជម្រះសាលា ដំបូង បានទទួលស្គាល់ដោយប្រយោលថា ការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ មិនមែនជាការបង្ហាញភស្តុតាងនោះទេ។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា៖ “បន្ទាប់ពីសវនាការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នេះបានបញ្ចប់ហើយ សវនាការ

**បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលជំនុំជម្រះក្តី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់**

ដែលជានីតិវិធី មិនធ្លាប់បានអនុវត្តក្នុងប្រព័ន្ធបារាំង/Civil Law ប៉ុន្តែត្រូវបានអនុម័តដោយថៅក្រមក្នុងអំឡុងកិច្ចប្រជុំពេញអង្គ[១០៥] គ្រាន់តែជាការពិនិត្យមើលជាមុននូវរឿងក្ដី និងភស្តុតាងដែល ភាគីរំពឹងថានឹងដាក់បង្ហាញ ហើយជារឿយៗត្រូវបានធ្វើឡើង គ្រាន់តែជាការបង្ហាញ និងដើម្បីទទួលបានការចាប់អារម្មណ៍តែប៉ុណ្ណោះ[១០៦] ។ មិនមានភាពចាំបាច់ណាមួយដែលថា លោក អៀង សារី ត្រូវមាន វត្តមានដើម្បីស្ដាប់សេចក្ដីសន្និដ្ឋានបើក ដែលមិនមែនជាភស្តុតាងនោះទេ។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានជូនដំណឹងរួចហើយថា លោក អៀង សារី មិនមានបំណងនឹងផ្ដល់សក្ខីកម្មនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនាពេលនោះឡើយ[១០៧] ហេតុដូច្នេះ គាត់មិនចាំបាច់ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការឡើយ។ វត្តមានរបស់ លោក អៀង សារី ឬអវត្តមានរបស់គាត់នៅក្នុងបន្ទប់សវនាការ នឹងមិនឥទ្ធិពលអ្វីចំពោះថាតើសវនាការសម្រាប់សេចក្ដីសន្និដ្ឋានបើក ការចោទប្រកាន់អាចដំណើរការបានដែរឬទេ ឬថាតើកិច្ចដំណើរការនេះដំណើរការទៅបានដោយរបៀបណានោះឡើយ។ ការិយាល័យសហព្រះរាជអាជ្ញា ក្រុមមេធាវី

---

បង្ហាញភស្តុតាងនៅក្នុងសំណុំរឿង ០០២ នឹងចាប់ផ្ដើមនៅថ្ងៃ ច័ន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ វេលាម៉ោង ៩ ព្រឹក"។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ១ ដែល លោក Michael G. Karnavas សហមេធាវីការពារក្ដីអន្តរជាតិសម្រាប់ លោក អៀង សារី បានលើកឡើងថា៖ "សេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់ មិនមែនជាការបង្ហាញភស្តុតាងទេ... [សេចក្ដីសន្និដ្ឋានទាំងនេះ] មិនមានមែនជាផ្នែក ដ៏សំខាន់មួយនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលគ្មានពុំបាននោះទេ។ ខ្ញុំយល់ថាអ្វីដែលសំខាន់ខានពុំបាននោះ គឺជាសិទ្ធិរបស់ជនជាប់ចោទម្នាក់ ក៏ដូចជាសិទ្ធិរបស់ភាគីនានាផងដែរ"។ អង្គជំនុំជម្រះសាលាដំបូង មិនបានជំទាស់ទៅនឹងការលើកឡើងនេះទេ។

[១០៥] វិធាន ៨៩ ស្ទួន (២) អនុម័តក្នុងអំឡុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៨ ចែងថា "នៅមុនពេលសួរចម្លើយ សហព្រះរាជអាជ្ញា អាចធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន"។

[១០៦] *សូមមើល ឧទាហរណ៍* សេចក្ដីសន្និដ្ឋានបើករបស់លោក Andrew Cayley សហព្រះរាជអាជ្ញាអន្តរជាតិ ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ១០៨-១៣៣ និងប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ២១-៦៨។ ក្រៅពីធ្វើសេចក្ដីសន្និដ្ឋានបើកដោយប្រើសំដីអុជអាល។ ផ្នែកភាគច្រើននៃសេចក្ដីសន្និដ្ឋានបើករបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាការលើកឡើងពីទឡ្ហីករណ៍ ហាក់បីដូចជាការសង្ខេបនូវភស្តុតាង ឬការធ្វើសេចក្ដីសន្និដ្ឋានបិទអញ្ចឹង។

[១០៧] *សូមមើល* សេចក្ដីកត់សម្គាល់របស់ លោក អៀង សារី ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ថា លោក អៀង សារី មិនមានបំណងផ្ដល់សក្ខីកម្មក្នុងអំឡុងពេលសវនាការនោះទេ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E101/4។

ការពារក្តីដទៃទៀត ឬសហជនជាប់ចោទ អាចបង្ហាញសេចក្តីសន្និដ្ឋានបើក ឬការលើកឡើងផ្សេងៗរបស់ខ្លួនបាន មិនថាលោក អៀង សារី មានវត្តមានដោយផ្ទាល់ ឬ មិនមានវត្តមាននៅទីនោះក៏ដោយ។

៥៣ លោក អៀង សារី មិនត្រូវបានតម្រូវឱ្យមានវត្តមាននក្នុងបន្ទប់សវនាការ ដើម្បីបង្ហាញសាធារណជន និងភាគីនានាឱ្យឃើញថា គាត់បានស្តាប់បទចោទប្រកាន់នានាប្រឆាំងលើរូបគាត់ឡើយ។ លោក អៀង សារី ត្រូវបានជូនដំណឹងរួចហើយអំពីបទចោទប្រកាន់នានាប្រឆាំងលើរូបគាត់នៅក្នុងសវនាការមុនៗ[១០៨]។ គាត់ក៏មានលទ្ធភាពអាចមើលដីកាដំណោះស្រាយជាច្រើនខែផងដែរ។ សវនាការសម្រាប់សេចក្តីសន្និដ្ឋានបើក មិនមែនជាឱកាសដំបូង ដែលសាធារណជន និងភាគីនានា ត្រូវសង្កេតមើលលោក អៀង សារី នៅក្នុងតុលាការនោះទេ។ ឧបករណ៍ប្រព័ន្ធសោតទស្សន៍នៅក្នុងបន្ទប់រង់ចាំ ត្រូវបានរៀបចំឡើងរួចហើយ ដើម្បីអាចឱ្យមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងជនជាប់ចោទ និងអ្នកនៅក្នុងបន្ទប់សវនាការ[១០៩] ហើយកន្លងមកក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី[១១០] មិនដែលបានលើកឡើងពីការជំទាស់ទៅនឹងការរៀបចំនោះឡើយ។

៥៤ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតសំអាងហេតុដោយអត្តនោម័ត ដើម្បីចាប់បង្ខំឱ្យ លោក អៀង សារី មានវត្តមាននៅក្នុងបន្ទប់សវនាការតាមរយៈសេចក្តីបង្គាប់របស់ខ្លួន។ ការអនុវត្តជាអន្តរជាតិ ឬវិធានផ្ទៃក្នុង មិនដាក់ទណ្ឌកម្ម លោក អៀង សារី ដោយមិនអនុញ្ញាត ឲ្យគាត់លះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការតាមរយៈការសម្រេចដោយអត្តនោម័តឡើយ។ តាមរយៈការបដិសេធដោយមានចេតនា និងដោយបានដឹងឮយ៉ាងច្បាស់ ក្នុងការទទួលស្គាល់ការលះបង់សិទ្ធិដោយមានសុពលភាពរបស់ លោក អៀង សារី ដែលគាត់បានលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់

[១០៨] កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីសវនាការដេញដោល ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ C19 ទំព័រ ២។ កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តាប់ចម្លើយជនជាប់ចោទ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ D282 ទំព័រ ៣ ដល់ទំព័រ ៥។ សវនាការបឋម ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ទំព័រ ១។

[១០៩] *សូមមើល* ប្រតិចារឹកកិច្ចប្រជុំរៀបចំសវនាការ ទំព័រ ២១-២២

[១១០] *ដូចជើងទំព័រខាងលើ* ទំព័រ ២៧ (ក.ស.ព) ទំព័រ ៤០ (ដើមបណ្តឹងរដ្ឋប្បវេណី)

សវនាការ និងតាមរយៈការចាប់បង្ខំឱ្យគាត់មានវត្តមាននៅក្នុងបន្ទប់សវនាការដោយលើកឡើងពីសំអាងហេតុដែលមិនមាននីត្យានុកូលភាពនោះ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។

**៣.ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា សិទ្ធិរបស់ លោក អៀង សារី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងជួយដល់ការការពារក្ដីរបស់គាត់ គឺជាសិទ្ធិត្រឹមត្រូវ នោះការដាក់កំហិតដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ គឺជាការដាក់កំហិតមិនសមាមាត្រទៅនឹងសំអាងហេតុសម្រាប់ការបដិសេធសំណើរបស់ លោក អៀង សារី ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ**

៩៥ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា សិទ្ធិរបស់ លោក អៀង សារី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងជួយដល់ការការពារក្ដីរបស់គាត់ គឺជាសិទ្ធិដ៏ត្រឹមត្រូវនោះ ការដាក់កំហិតនៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះ គឺជាការដាក់កំហិតមិនសមាមាត្រទៅនឹងយុត្តិកម្មដែលបានផ្ដល់ឱ្យអង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រដល់សំណើសុំលះបង់សិទ្ធិរបស់ លោក អៀង សារី ឡើយ ពីព្រោះមានជម្រើសមួយដែលអាចឱ្យ លោក អៀង សារី គឺការចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ។ អនុលោមតាមគោលការណ៍សមាមាត្រ "រាល់ការដាក់កំហិតណាមួយទៅលើសិទ្ធិជាសារវ័ន្ត ត្រូវធ្វើឡើងដើម្បីបម្រើដល់វត្ថុបំណងសំខាន់ចាំបាច់ និងមិនត្រូវឱ្យមានការប៉ះពាល់ដល់សិទ្ធិដទៃផ្សេងទៀត ក្រៅពីអ្វីដែលចាំបាច់ដើម្បីសម្រេចនូវវត្ថុបំណងនេះឡើយ"[១១១]។ មិនមានសំអាងហេតុណាមួយដែលរៀបរាប់នៅក្នុងសេចក្ដីសម្រេចដែលត្រូវបាន

[១១១] *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង* *Stanišić & Simatović* ឯកសារលេខ IT-03-69-AR73.2 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្ដីប្រឆាំងនឹងសេចក្ដីសម្រេចលើការប្រព្រឹត្តិទៅនាពេលអនាគតនៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨។ នៅក្នុងសំណុំរឿង *Stanišić* អង្គជំនុំជម្រះតុលាការជាន់ខ្ពស់បានច្រានចោលសេចក្ដីសម្រេចដែលផ្អែកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានតម្រូវឱ្យមានការសម្ដែងការគួរសម ហើយបានសម្រេចថាអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបាន "ផ្ដល់ការពិចារណាគ្រប់គ្រាន់ទៅលើសិទ្ធិមានវត្តមានរបស់ជនជាប់ចោទ

ជំទាស់នេះ បង្កើតបានទៅជាវត្ថុបំណងសំខាន់ចាំបាច់ ដែលអាចជាយុត្តិកម្មដោយមានសមាមាត្រសម្រាប់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ក្នុងការដកហូតនូវសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក អៀង សារី នោះ។ លោក អៀង សារី មិនអាចនៅអង្គុយក្នុងបន្ទប់សវនាការបាន ដោយសារតែស្ថានភាពសុខភាពរបស់គាត់ ជាពិសេសដោយសារតែការឈឺចាប់ខ្លាំងនៅត្រង់ខ្នងរបស់គាត់[១១២]។ លោក អៀង សារី ប្រាថ្នាចង់បន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងជួយដល់ការការពារក្តីរបស់គាត់។ បន្ទប់រង់ចាំនៅខាងក្រោមបន្ទប់សវនាការត្រូវបានរៀបចំឡើងសម្រាប់ស្ថានភាពជាក់លាក់នេះ[១១៣]។ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងធ្លាប់សម្រេច អនុញ្ញាតឱ្យ លោក អៀង សារី, អ្នកស្រី អៀង ធីរិទ្ធ និងលោក នួន ជា ត្រឡប់ទៅកាន់បន្ទប់រង់ចាំ ឬមន្ទីរឃុំឃាំង ដោយមូលហេតុសុខភាព ឬដោយមូលហេតុដទៃផ្សេងទៀតនោះ[១១៤] និងដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងកន្លងមកបានសម្រេចថាជនជាប់ចោទអាចបោះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការបាន ហើយអាចជ្រើសរើសចូលរួមពីបន្ទប់រងចាំនោះ[១១៥] ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងដោយមិនអនុញ្ញាតឱ្យ លោក អៀង សារី ធ្វើដូច្នោះនៅក្នុង សវនាការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នោះគឺជាការសម្រេចដោយអត្តនោម័ត មិនមានយុត្តិកម្ម និងរំលោភបំពានដល់គោលការណ៍សមាមាត្រ (ប្រសិនបើអាចអនុវត្តទៅបាន)។

---

និងបានផ្តល់ការពិចារណាមិនសមហេតុផលទៅលើវត្ថុបំណងនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធី” *ឯកសារដដែល* កថាខណ្ឌ ១៨។

[១១២] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ១ - ៣។

[១១៣] ទិដ្ឋភាពក្រៅសវនាការ៖ បន្ទប់រង់ចាំ *អាចអានបានតាមគេហទំព័រ http://www.eccc.gov.kh/en/articles/behind-scenes-holding-cells*។

[១១៤] *សូមមើលលេខយោងជើងទំព័រខាងលើ* សារតា។

[១១៥] ប្រតិចារឹកកិច្ចប្រជុំរៀបចំសវនាការ ទំព័រ ២១-២២, ប្រតិចារឹកសវនការបឋម ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ E1/4.1 ទំព័រ ៧៥ , ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ E1/12.1 ទំព័រ ១៣៦-១៣៧, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង

**បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលជំនុំជម្រះក្តី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់**

## គ. តាមរយៈសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយបំពានលើគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" (*nulla peona sine lege*)

៥៦ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ដោយបង្ខំឲ្យលោកអៀង សារី មានវត្តមានក្នុងបន្ទប់សវនាការនៅពេលដែលគាត់មានអាការៈឈឺចាប់លើរាងកាយយ៉ាងខ្លាំង ដែលជាការបំពានលើគោលការណ៍ គ្មានទោសបើគ្មានច្បាប់ចែង។ ធាតុផ្សំនៃគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" ត្រូវបានចែងយ៉ាងច្បាស់ក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ការបង្ខិតបង្ខំ ការធ្វើបាបលើរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ[១១៦]" និងមាត្រា ១៥ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ គោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" តម្រូវថា ការដាក់ទណ្ឌកម្មព្រហ្មទណ្ឌណាមួយត្រូវមាន*ចែង*យ៉ាងច្បាស់ក្នុងច្បាប់[១១៧]។ អ្នកអត្ថាធិប្បាយល្បីៗយល់ឃើញថា បទប្បញ្ញាតិនៃគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង"នៃមាត្រា ១៥ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ៧ (១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ជាការបង្កើតឲ្យមាន *lex scripta* (ច្បាប់ជាលាយ លក្ខណ៍អក្សរ) *lex certa* (ជាក់លាក់ និងអាចព្យាករណ៍បាន) និង *lex stricta* (ហាមឃាត់ សទិសភាព) ដែលជាលក្ខណៈកំណត់នៃគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" ក្រៅពីការ ដាក់បញ្ចូលយ៉ាងច្បាស់នូវ *lex praevia* [១១៨] (ការហាមឃាត់នូវប្រតិសកម្ម)។ គោលការណ៍ "គ្មានទោសបើគ្មាន

---

[១១៦] រដ្ឋធម្មនុញ្ញ ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា "ការបង្ខិតបង្ខំ ការធ្វើបាបរូបរាងកាយ ឬប្រព្រឹតកម្មណាដែលបន្ថែមទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់"។

[១១៧] រឿងក្តី *Baskaya & Okçuoğlu* តទល់នឹង *Turkey*, Eur. Ct. H. R. App. Nos. 23536/94 & 24408/94, ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៣៦។

[១១៨] *សូមមើលផងដែរ* Shahram Dana, *Beyond Retroactivity to Realizing Justice: A Theory on the Principle Of Legality in International Criminal Law Sentencing*, 99(4) JOURNAL OF CRIMINAL LAW & CRIMINOLOGY, 857, 868: *ទាញសំអាងពី* MANFRED NOWAK, U.N. COVENANT ON CIVIL AND POLITICAL RIGHTS: CCPR COMMENTARY 359-60 (2d ed. 2005) (1993)

ច្បាប់ចែង" ជាការគាំពារដែលរារាំងមិនឲ្យមានកត្តានានា ដូចជា បុរេនិច្ឆ័យ ជាទូទៅ សម្ពាធនយោបាយ ឬមតិសាធារណៈជនដែលលើកឡើងភ្លាមៗ មានឥទ្ធិពលលើការ កំណត់ដាក់ទោសដើម្បីការពារសុច្ចរិតភាពនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ[១១៩]។ ការដាក់ទណ្ឌកម្មជាការសងសឹកដែលបង្ខំឲ្យជនជាប់ចោទមួយរូបទទួលរងការដាក់ទោសមុនពេលត្រូវ បានផ្តន្ទាទោសតាមច្បាប់ជាការរំលោភគោលការណ៍នេះ។

៥៧ ដើម្បីបំពេញចិត្តសាធារណជន និងភាគី អង្គជំនុំជម្រះសាលាដំបូងបានចាប់បង្ខំ លោក អៀង សារី ដែលជាបុគ្គលមានវ័យចំណាស់ អាយុ ៨៦ ឆ្នាំ និងមានជម្ងឺប្រចាំកាយ ឱ្យមានវត្តមានដើម្បីជាការដាក់បង្ហាញនៅក្នុងបន្ទប់សវនាការ។ ទោះបីលោកអៀង សារី មិនទាន់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយក៏ដោយ ដោយតម្រូវឲ្យគាត់មានវត្តមានក្នុងបន្ទប់សវនាការ និងទ្រាំទ្រនឹងការឈឺចាប់លើរាងកាយ ជាជាងអនុញ្ញាតឲ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តអ្វីដែលគេមើលឃើញថាជាការដាក់ទណ្ឌកម្មយ៉ាងព្រៃផ្សៃ និងខុសប្រក្រតី។ សេចក្តីសម្រេចដែលរងការជំទាស់នេះ ស្មើនឹងការដាក់ទោសតាមការរំពឹងទុក ឬការប្រើអំណាចដោយមិនត្រឹមត្រូវ ជាជាងការអនុវត្តច្បាប់។ សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូង មិនអាចផ្សះផ្សាបានជាមួយគោលការណ៍សច្ចធារណ៍នៃនិរទោស[១២០]ឡើយ ឬគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" ឡើយ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ មានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងសញ្ញាណនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចត្រូវបានធានាក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក វិធាន និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

---

[១១៩] *ដូចជើងទំព័រខាងលើ* ៨៦៤ "វិធីសាស្ត្រទំនើបចំពោះគោលការណ៍នីត្យានុកូលភាពជាអនុវត្តគោលការណ៍*គ្មានទោសបើគ្មានច្បាប់ចែង (nulla poena)* មិនសម្រាប់តែដាក់កម្រិតសិទ្ធិអំណាចរបស់តុលាការទេ ថែមទាំងជាការគាំពារដែលរារាំងមិនឲ្យមានកត្តានានា ដូចជាបុរេនិច្ឆ័យជាទូទៅ សម្ពាធនយោបាយ ឬមតិសាធារណៈជនដែលលើកឡើងភ្លាមៗ មានឥទ្ធិពលលើការកំណត់ទោសទណ្ឌ។ វាទប់ស្កាត់ការគំរាមកំហែងទាំងនេះដែលអាចកើតឡើងចំពោះយុត្តិធម៌ក្នុងការកំណត់ទោសទណ្ឌបានមួយចំណែក និងទប់ស្កាត់មិនឲ្យមានការជះឥទ្ធិពលបែបនេះ។ អាស្រ័យហេតុនេះ ក្រៅពីគាំពារសិទ្ធិរបស់ជនជាប់ចោទ គោលការណ៍*គ្មានទោស បើគ្មានច្បាប់ចែង* ក៏ការពារសុច្ចរិតភាពនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។

[១២០] *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨, ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា ៣៥ ថ្មី, កិច្ចព្រមព្រៀង មាត្រា ១៣ (១), វិធាន ២១ (១) (ឃ) និង ICCPR មាត្រា ១៤ (២)

**ឃ. តាមរយៈសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ដោយបានអនុវត្តវិធានការបង្ខំ ដែលមិនកម្រិតតឹងរឹងបំផុតសម្រាប់តម្រូវការចាំបាច់នៃកិច្ចដំណើរការនិតិវិធី និងមិនគោរពយ៉ាងពេលលេញនូវសេចក្ដីថ្លៃថ្នូរជាមនុស្សរបស់លោកអៀង សារី**

៥៨ ដោយចាប់បង្ខំឱ្យ លោក អៀង សារី ត្រូវមានវត្តមាននៅក្នុងតុលាការ ខណៈដែលគាត់មានការឈឺចាប់ផ្នែករាងកាយខ្លាំងនោះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធានការបង្ខំ ដែលមិនកម្រិតតឹងរ៉ឹងបំផុតសម្រាប់តម្រូវការនៃកិច្ចដំណើរការនីតិវិធីនិងមិនបានគោរពសេចក្ដីថ្លៃថ្នូរជាមនុស្សរបស់លោកអៀង សារី ឱ្យបានពេញលេញនោះផងដែរ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ចែងថា "ច្បាប់ការពារជីវិត សេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ"។ អ.វ.ត.ក បានអនុម័តយកគោលការណ៍នៃការគោរពសេចក្ដីថ្លៃថ្នូរជាមនុស្សនេះក្នុងអំឡុងកិច្ចដំណើរការនីតិវិធីរបស់ខ្លួន៖ វិធាន២១(២) ដាក់កំហិតលើការអនុវត្តនូវ "វិធានការបង្ខំ" ជនជាប់ចោទ តែចំពោះករណីដែលកម្រិតតឹងរឹងបំផុតសម្រាប់តម្រូវការចាំបាច់នៃកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ និងត្រូវគោរពសេចក្ដីថ្លៃថ្នូរជាមនុស្សឱ្យបានពេញលេញ។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "កើតមកពីសេចក្ដីថ្លៃថ្នូរដែលមានស្រាប់របស់បុគ្គលម្នាក់ៗក្នុងនាមជាមនុស្ស"[១២១] ព្រោះថាការការពារសិទ្ធិមនុស្សផ្អែក "ដោយផ្ទាល់លើមូលដ្ឋាននៃសីលធម៌ ជំនឿដែលថា មនុស្សគ្រប់រូបដែលមានរូបមានរាងកាយ សុទ្ធតែមានសិទ្ធិទទួលបាននូវសិទ្ធិ និងសេរីភាពជាមូលដ្ឋានជាក់លាក់មួយចំនួន ហើយក្នុងករណីមួយចំនួន គឺជាសិទ្ធិ និងសេរីភាពឥតដែនកំណត់ផង ដែរ"[១២២]។ ។ អាស្រ័យហេតុនេះ

---

[១២១] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បុព្វកថា។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងតម្រូវថា តុលាការកម្ពុជា "ត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ កតិកាសញ្ញានេះរួមទាំងកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាគឺជាភាគីមួយផងដែរ។

[១២២] សៀវភៅរបស់ Lord Bingham of Cornhill ដែលមានចំណងជើងថា The Rule of Law (នីតិរដ្ឋ) លេខ ១១៦ (បោះពុម្ពផ្សាយដោយរោងពុម្ព Penguin Books នៅឆ្នាំ ២០១០)។ សារសំខាន់ជាមូលដ្ឋានសេចក្ដីថ្លៃថ្នូរបស់មនុស្ស ក៏ត្រូវបានបញ្ជាក់ច្បាស់ក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលថ្លែងថាគោលដៅចំបងរបស់អង្គការសហប្រជាជាតិ គឺ "បញ្ជាក់ជាថ្មីនូវ

សេចក្តីថ្លៃថ្នូរជាមនុស្ស ជាសិទ្ធិមនុស្ស គឺជា "តម្លៃសជ្ឈន្តិករមួយ ស្មើៗគ្នាសម្រាប់មនុស្សគ្រប់រូប ដែលកើតចេញពីគុណតម្លៃជាក់លាក់នានារបស់មនុស្ស លោក... សេចក្តីថ្លៃថ្នូរដែលមានស្រាប់នេះ មិនអាចត្រូវបានជំនួសជាមួយនឹងអ្វីផ្សេងពីនេះឡើយ ហើយក៏មិនអាចធៀបពាក់ព័ន្ធនឹងបំណង ឬ មតិយោបល់របស់នរណាម្នាក់បានដែរ"[១២៣]។ ភាពមិនអាចរំលោភបំពានបាននៃសេចក្តីថ្លៃថ្នូរជាមនុស្សនេះ គឺជាគ្រឹះនៃច្បាប់មូលដ្ឋានក្រោយសង្គ្រាមលោកលើកទីពីររបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់[១២៤] និងបានគូសបញ្ជាក់អំពីកាតព្វកិច្ចរបស់រដ្ឋាភិបាលប្រទេសនេះចំពោះពលរដ្ឋរបស់ខ្លួន ដែលអ្នកសិក្សាស្រាវជ្រាវបានកត់សម្គាល់ឃើញថា ចំណុចស្នូលនៃការអនុវត្តបែបនេះកើតចេញ

---

ការជឿជាក់លើសិទ្ធិមនុស្សជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូរ និងគុណតម្លៃរបស់មនុស្ស..." ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ 1 U.N.T.S. XVI, បុព្វកថា (ចុះហត្ថលេខាថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៤៥)

១២៣ អត្ថបទរបស់ លោក Alan Gewirth ដែលមានចំណងជើងថា *Human Dignity as the Basis of Rights* (សេចក្តីថ្លៃថ្នូរជាមនុស្សគឺជាមូលដ្ឋាននៃសិទ្ធិនានា) ផ្សាយនៅក្នុងសៀវភៅ ដែលមានចំណងជើងថា The Constitution of Rights: Human Dignity and American Values (ធម្មនុញ្ញភាពនៃសិទ្ធិនានា៖ សេចក្តីថ្លៃថ្នូរជាមនុស្ស និងគុណតម្លៃរបស់ជនជាតិអាមេរិក) លេខ ១០ ទំព័រ ១២ ដល់ ១៣ (បោះពុម្ពផ្សាយដោយរោងពុម្ព Cornell University Press នៅឆ្នាំ ១៩៩២)។

១២៤ មាត្រា ១ នៃច្បាប់មូលដ្ឋានរបស់សធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (អនុម័តនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៤៩) ចែងថា៖ "(១) មិនត្រូវរំលោភបំពានលើសេចក្តីថ្លៃថ្នូរជាមនុស្សឡើយ។ កាតព្វកិច្ចរបស់អាជ្ញាធររដ្ឋទាំងអស់ គឺត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូរជាមនុស្សនេះ"។ ច្បាប់មូលដ្ឋានរបស់ប្រទេសនេះ ភ្ជាប់ទំនាក់ទំនងរវាងសេចក្តីថ្លៃថ្នូរជាមនុស្ស និងសិទ្ធិមនុស្ស ហើយចែងថា "សិទ្ធិមនុស្សដែលមិនអាចរំលោភបំពាន និងមិនអាចដកហូតបាននោះ" គឺជាមូលដ្ឋាននៃសហគមន៍នីមួយៗ សន្តិភាព និងយុត្តធម៌ នៅលើពិភពលោក។ *ឯកសារដដែល* មាត្រា ១ (២) អាចរកបានតាមរយៈ (១)-(២) https://www.btg-bestellservice.de/pdf/80201000.pdf (អនុម័តថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ១៩៤៩)។ សេចក្តីថ្លៃថ្នូរជាមនុស្សបង្កើតបានជា "គុណតម្លៃផ្លូវច្បាប់ដ៏ខ្ពស់បំផុតនៅក្នុងប្រទេសអាល្លឺម៉ង់"។ *សូមមើល* សៀវភៅរបស់ N. Rao ដែលមានចំណងជើងថា *On the Use and Abuse of Dignity in Constitutional Law* (*ការអនុវត្ត និងការរំលោភបំពានលើសេចក្តីថ្លៃថ្នូរនៅក្នុងច្បាប់ធម្មនុញ្ញ*) លេខ ១៤ បោះពុម្ពផ្សាយដោយ Col. J. Eur. L. ទំព័រ ២០១ និង ២១៦ (ឆ្នាំ ២០០៨) ដែលបានយោងឯកសាររបស់ Edward J. Eberle ស្តីពី Dignity and Liberty: Constitutional Visions in Germany and the United States (សេចក្តីថ្លៃថ្នូរ និងសេរីភាព៖ ទស្សនៈរដ្ឋធម្មនុញ្ញនៅក្នុងប្រទេសអាល្លឺម៉ង់ និងសហរដ្ឋអាមេរិក) លេខ ៤២ (បោះពុម្ពផ្សាយដោយ Praeger ឆ្នាំ ២០០២)។

ពីអំពើដ៏រន្ធត់របស់ពួកណាស៊ី (Nazi) អាល្លឺម៉ង់[១២៥]។ ការការពារសេចក្តីថ្លៃថ្នូរ ដូចបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ[១២៦] អាចឱ្យគេមើលឃើញថាជាការកកើតឡើងស្រដៀងគ្នានេះដែរ ដែលចេញពីការធ្លាក់ចុះអន់ថយ "យ៉ាងខ្លាំង" និង "ទុក្ខវេទនា និងការបំផ្លិចបំផ្លាញ" របស់កម្ពុជានៅក្នុងអំឡុង "ពីរទសវត្សរ៍" មុនពេលមានរដ្ឋធម្មនុញ្ញ[១២៧]។

៥៩ តាមរយៈការចាប់បង្ខំឱ្យ លោក អៀង សារី មានវត្តមាននៅក្នុងតុលាការ ខណៈពេលដែលគាត់មិនស្រួលខ្លួន និងមានការឈឺចាប់ផ្នែករាងកាយនោះ អង្គជំនុំជម្រះសាលាដំបូងបានដកហូតសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ លោក អៀង សារី ដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ បានកាត់បន្ថយការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់ លោក អៀង សារី មកត្រឹមជាការបង្ហាញរូបគាត់ជាសាធារណៈ ដែលធ្វើឱ្យគាត់ក្លាយជាវត្ថុដែលគេចង់ឃើញដើម្បីបំពេញតម្រូវចិត្ត និងសេចក្តីរីករាយរបស់សាធារណជន ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះជាន់ឈ្លីចំពោះទស្សនទាននៃយុត្តិធម៌ ភាពត្រឹមត្រូវ និងភាពសមរម្យ ដែល អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បីបង្ហាញគំរូទាំងនេះ និងខកខានមិនបានគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សដែលតុលាការនេះត្រូវការពារនោះទេ។

**ង. អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ហើយបានបង្កឱ្យមានព្យសនកម្មលើ លោក អៀង សារី ដោយសារអង្គជំនុំជម្រះបានរំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌**

---

[១២៥] សៀវភៅរបស់ N. Rao ដែលមានចំណងជើងថា *On the Use and Abuse of Dignity in Constitutional Law* (*ការអនុវត្ត និងការរំលោភបំពានលើសេចក្តីថ្លៃថ្នូរនៅក្នុងច្បាប់ធម្មនុញ្ញ*) លេខ ១៤ បោះពុម្ពផ្សាយដោយ Col. J. Eur. L. ទំព័រ ២០១ និង ២០៧ (ឆ្នាំ ២០០៨)។

[១២៦] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។

[១២៧] រដ្ឋធម្មនុញ្ញកម្ពុជា បុព្វកថា។

៦០ បើទោះជា លោក អៀង សារី ស្ថិតនៅក្នុងស្ថានភាពលំបាក និងមានការឈឺចាប់ខ្លាំង ដែលមិនអាចឱ្យគាត់ចូលរួមកិច្ចដំណើរការនីតិវិធីដោយមានស្មារតីគ្រប់គ្រាន់បែបនោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានចាប់បង្ខំឱ្យគាត់ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ និងត្រូវដាក់បង្ហាញរូបគាត់ ដើម្បីឱ្យសាធារណជន និងភាគីនានា អាចសង្កេតមើលថាគាត់បានស្តាប់ឮបទចោទប្រកាន់នានាប្រឆាំងលើរូបគាត់[១២៨]។ ដើម្បីឲ្យត្រូវនឹងការរំពឹងទុកជាមូលដ្ឋានរបស់សាធារណជន តាមវិធីនេះ ដែលត្រូវបានមើលឃើញថា រៀបចំឡើងជាការសងសឹកយ៉ាងច្បាស់ក្រឡែតមុនពេលផ្តន្ទាទោសតាមច្បាប់ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយន្តការចាប់បង្ខំមកលើលោក អៀង សារី ដែលមិនកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី បានខកខានក្នុងការគោរពឱ្យបានពេញលេញនូវសេចក្តីថ្លៃថ្នូរជាមនុស្សរបស់គាត់ និងបានរំលោភបំពានលើគោលការណ៍ "មិនមានទោសបើគ្មានច្បាប់ចែង" ផងដែរ។ សេចក្តីប្រាថ្នា និងការរំពឹងទុករបស់សាធារណជន និងភាគីនានា មិនពាក់ព័ន្ធទៅនឹងសិទ្ធិជាសារវ័ន្តរបស់ លោក អៀង សារី ដើម្បីទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ និងមិនពាក់ព័ន្ធទៅនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាឱ្យបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌នោះឡើយ។ សេចក្តីប្រាថ្នា និងការរំពឹងទុកទាំងនោះ មិនមានសារៈសំខាន់ជាងសិទ្ធិជាសារវ័ន្តរបស់ លោក អៀង សារី ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងក្នុងការការពារក្តីរបស់ខ្លួន ក្នុងការទទួលបាននូវការគោរពឱ្យបានពេញលេញលើសេចក្តីថ្លៃថ្នូរជាមនុស្សរបស់គាត់ និងក្នុងការជៀសផុតពីយន្តការចាប់បង្ខំនានា ដែលមិនមានចែងនៅក្នុងច្បាប់ ឬដែលមិនត្រូវបានកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃកិច្ចដំណើរការនីតិវិធីនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពិចារណាលើកត្តានានាដែលមិនពាក់ព័ន្ធ ហើយមិនបានពិចារណាលើកត្តាពាក់ព័ន្ធទេ នៅពេលចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់មួយនេះ។

៦១ តាមរយៈការសម្រេចតម្រូវឱ្យ លោក អៀង សារី ត្រូវបង្ហាញខ្លួនជាសាធារណៈ ជាជាងការសម្រេចឱ្យគាត់តាមដាន និងចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំដែលមានបំពាក់ឧបករណ៍

[១២៨] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ទំព័រ ៣៦ និងប្រតិចារឹក ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ទំព័រ ៨។

ជាពិសេសនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងយ៉ាងជាក់ច្បាស់នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដែលកំហុសឆ្គងនេះបណ្តាលឱ្យ លោក អៀង សារី ទទួលរងនូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរ[១២៩]។ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តតាមយុត្តិសាស្ត្រ ដែលមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីស្តីពីបទដ្ឋាននៃការរំលោភបំពានលើឆន្ទានុសិទ្ធិ។ នៅក្នុងសំណុំរឿង *Prlić និងអ្នកដទៃទៀត* អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការ ICTY បានសម្រេចថា ការរំលោភបំពានលើឆន្ទានុសិទ្ធិកើតមានឡើង នៅពេលដែលសេចក្តីសម្រេចដែលត្រូវបានជំទាស់ "មានលក្ខណៈអយុត្តិធម៌ ឬមិនសមហេតុផលខ្លាំង... [ដោយសារ តែ] អង្គជំនុំជម្រះសាលាដំបូងផ្តល់សារៈសំខាន់ដល់កត្តាមិនពាក់ព័ន្ធ ឬខកខានមិនបានផ្តល់សារៈ សំខាន់ ឬសារៈសំខាន់គ្រប់គ្រាន់ដល់កត្តាពាក់ព័ន្ធនានា"[១៣០]។

៦២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចតាមសេចក្តីប្រាថ្នារបស់សាធារណជន និងភាគី ដោយមិនអើពើលើស្ថានភាពសុខភាពរបស់ លោក អៀង សារី ដែលមានកំណត់ត្រាច្បាស់លាស់ និងផលប៉ះពាល់នៃស្ថានភាពទាំងនោះមកលើសមត្ថភាពរបស់គាត់នៅក្នុងការអនុវត្តសិទ្ធិជាសារវ័ន្ត ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់ នៅពេលដែលគាត់អង្គុយនៅក្នុងបន្ទប់

---

[១២៩] *សូមមើល* វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[១៣០] *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃទៀត* ឯកសារលេខ IT-04-74-AR65.24 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Jadranko Prlić ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិរបស់គាត់ស្នើសុំឱ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៤ *ដោយមានយោងលើ សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង* Vujadin Popović *និងអ្នកដទៃទៀត* ឯកសារលេខ IT-05-88-AR65.10 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Radivoje Miletić ប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិរបស់គាត់ស្នើសុំឱ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៤ និង ៥។ *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃទៀត* ឯកសារលេខ IT-04-74-AR65.24 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Jadranko Prlić ប្រឆាំងនឹងសេចក្តីសម្រេច *Décision Relative à la demande de mise en liberté provisoire de l'accusé Prlić* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០០៩ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៥ និង ៦។ *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង* Vujadin Popović *និងអ្នកដទៃទៀត* ឯកសារលេខ IT-05-88-AR65.7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់ *Vujadin Popović* ប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិរបស់ *Popović* ស្នើសុំឱ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៦។

សវនាការនោះទេ ហើយអង្គជំនុំជម្រះក៏មិនអើពើលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការគោរពលើសេចក្ដីថ្លៃថ្នូ និងគោលការណ៍ "គ្មានទោសបើគ្មានច្បាប់ចែង" នោះដែរ។ ដោយពិចារណាទៅលើការរកឃើញ និងអនុសាសន៍របស់អ្នកជំនាញ លោកសាស្ត្រាចារ្យ Campbell ដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងនោះ និងដោយពិចារណាទៅលើអង្គហេតុដែលថា បន្ទប់រង់ចាំមានពាក់នូវឧបករណ៍ជាពិសេសដើម្បីសម្រួលដល់ស្ថានភាពសុខភាពរបស់ជនជាប់ចោទ ស្ថានភាពសុខភាពរបស់ លោក អៀង សារី គឺជាកត្តាពាក់ព័ន្ធខ្លាំងមួយ ដែលអង្គជំនុំជម្រះសាលាដំបូងគួរបានយកមកពិចារណានៅក្នុងការចេញសេចក្ដីសម្រេចលើបញ្ហានេះ។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងចាប់បង្ខំឱ្យ លោក អៀង សារី ត្រូវតែមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនោះ អង្គជំនុំជម្រះបានរារាំងដោយដឹងជាមុន និងដោយមានចេតនា ចំពោះលោក អៀង សារី មិនឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយមានស្មារតីគ្រប់គ្រាន់ និងអាចជួយដល់ការការពារក្ដីរបស់គាត់ ដែលជាលទ្ធផលធ្វើឱ្យគាត់ទទួលរងនូវព្យសនកម្ម។

## VI. សេចក្ដីសន្និដ្ឋាន និងសំណើសុំ

៦៣ តាមរយៈសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានដកហូតសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីឱ្យមានប្រសិទ្ធភាព និងការជួយដល់ការការពារក្ដីរបស់គាត់។ ដោយចាប់បង្ខំ លោក អៀង សារី ឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការដើម្បីផលប្រយោជន៍របស់សាធារណជន និងភាគីដទៃទៀត និងដោយមិនពិចារណាលើការលះបង់សិទ្ធិមានវត្តមានរបស់គាត់នោះ អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងការការពារសិទ្ធិរបស់ លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះទេ អង្គជំនុំជម្រះសាលាដំបូងក៏បានបន្ទាបតម្លៃនៃសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌នេះ ឱ្យទាបជាងការរំពឹងទុករបស់សាធារណជន និងភាគីនានាផងដែរ។ ដូចដែលចៅក្រម Schomburg នៃអង្គជំនុំជម្រះតុលាការជាន់ខ្ពស់របស់តុលាការ ICTY/ICTR បានកត់សម្គាល់យ៉ាងសមស្របថា "សហគមន៍អន្តរជាតិបានសម្រេចទទួលស្គាល់ថា ជនជាប់ចោទ *មិនត្រូវក្លាយ*

*ជាវត្ថុដ៏សាមញ្ញមួយនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ*[១៣១]។ នៅក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូង មិនគ្រាន់តែបានចាត់ទុកលោកអៀង សារី ជាវត្ថុមួយប៉ុណ្ណោះទេ ប៉ុន្តែជាវត្ថុមួយសម្រាប់បំពេញតម្រូវចិត្តចង់ឃើញចង់ដឹង នៅពេលសំដែងលើឆាក ដើម្បីតម្រូវចិត្តទស្សនិកជនដែលចង់ឲ្យមានការដាក់ទណ្ឌកម្មលើរូបគាត់ ។ អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាមិនគិតគូរពីផលប៉ះពាល់ដែលធ្វើឲ្យអន្តរាយដោយសារការប្រព្រឹត្តបែបនេះលើភាពត្រឹមត្រូវនៃការជំនុំជម្រះក្តី និងធម្មានុរូបភាពរបស់អ.វ.ត.កទាំងមូល។

៦៤ ដូចដែលតុលាការកំពូលរបស់សហរដ្ឋអាមេរិកបានកត់សម្គាល់យ៉ាងច្បាស់ហើយថា "សេចក្តីថ្លៃថ្នូរ សណ្តាប់ធ្នាប់ និងការគួរសម" គួរតែជាគុណតម្លៃនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ[១៣២]។ ការគោរពចំពោះគោលការណ៍នេះ ក៏អនុវត្តដូចគ្នានៅក្នុងកិច្ចដំណើរការ នីតិវិធីរបស់ អ.វ.ត.ក ផងដែរ។ ទោះជាយ៉ាងណា តាមរយៈសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើសិទ្ធិរបស់លោកអៀង សារី ដែលត្រូវផ្តល់សេចក្តីថ្លៃថ្នូរជាមនុស្ស *និង*សិទ្ធិទទួលបានជំនុំជម្រះក្តីតាមកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ ដែលធានាដោយរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងក៏បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការដោយចេតនា និងដឹងឮយ៉ាងជាក់ច្បាស់ផងដែរ។ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ហើយបានរំលោភបំពាន

---

[១៣១] *សូមមើល* មតិជំទាស់ដ៏សំខាន់របស់ចៅក្រម Schomburg ស្តីពីសិទ្ធិតំណាងឱ្យខ្លួនឯង កថាខណ្ឌ ៣ *នៅក្នុងសំណុំរឿង រដ្ឋអាជ្ញា តទល់នឹង Krajišnik* ឯកសារលេខ IT-00-39-A សេចក្តីសម្រេចលើសំណើសុំរបស់ Momcilo Krajišnik ដើម្បីតំណាងឱ្យខ្លួនឯង សេចក្តីសម្រេចលើញត្តិរបស់មេធាវីពាក់ព័ន្ធនឹងការចាត់តាំងអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី និងសេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាដាក់នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧, ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ (គូសបញ្ជាក់បន្ថែម)។

[១៣២] *សំណុំរឿង Illinois តទល់នឹង Allen* លេខ ៣៩៧ U.S. ទំព័រ ៣៣៧ និង ៣៤៣ (ឆ្នាំ ១៩៧០)៖ "សារៈសំខាន់សម្រាប់រដ្ឋបាលតុលាការព្រហ្មទណ្ឌល្អ គឺថាសេចក្តីថ្លៃថ្នូរ សណ្តាប់ធ្នាប់ និងភាពសមគួរ គឺជាគុណតម្លៃនៃរាល់កិច្ចដំណើរការនីតិវិធីតុលាការទាំងអស់..."។

លើឆន្ទានុសិទ្ធិរបស់ខ្លួននោះ អង្គជំនុំជម្រះតុលាការកំពូលគួរកែតម្រូវភាពអយុត្តិធម៌ ដែលបង្កឡើងដោយសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ ឱ្យបានលឿនដោយឆន្ទៈ។

**អាស្រ័យហេតុនេះ** សម្រាប់រាល់សំអាងហេតុដែលបានរៀបរាប់នៅក្នុងបណ្តឹងសាទុក្ខនេះ ក្រុមមេធាវីការពារក្តី សូមស្នើដោយគោរពឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

ក. **សម្រេចទទួលយក**បណ្តឹងសាទុក្ខនេះ។

ខ. **សម្រេចអនុញ្ញាត**ឱ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ លើបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ។

ឃ. **សម្រេច**ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយចាប់បង្ខំឱ្យ លោក អៀង សារី ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ និងដោយបដិសេធមិនអនុញ្ញាតឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ ដែលមានបំពាក់ឧបករណ៍ជាពិសេសនោះ។ និង

ង. **ធ្វើមោឃភាព**រាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានជំទាស់នេះ។

**ដោយសេចក្តីគោរព**

____________________ ____________________

**អាង ឧត្តម** **Michael G. KARNAVAS**

**សហមេធាវីការពារក្តីរបស់ លោក អៀង សារី**

ចុះហត្ថលេខានៅទីក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២